# ធាតុពិតនៃឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ



ខែមីនា ឆ្នាំ២០១៧

ធាតុពិតនៃឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ

© រក្សាសិទ្ធិដោយ សមាគមមណ្ឌលព័ត៌មានកម្មករ ខែមីនា ឆ្នាំ២០១៧

# មាតិកា


សេចក្តីថ្លែងអំណរគុណ ..... ទំព័រទី ៣

សេចក្តីផ្តើម ..... ទំព័រទី ៥

**ផ្នែកទី១៖ ស្ថានភាពសុខភាព និងអនាម័យ**

១.១ ស្ថានភាពសុខភាព និងអនាម័យ ..... ទំព័រទី ១១

១.១.១ ស្ថានភាពសុខភាពរបស់កម្មករ ..... ទំព័រទី ១១

១.១.២ ការប្រើប្រាស់សេវាសុខភាព និងតម្លៃព្យាបាល ..... ទំព័រទី ១១

១.២ អនាម័យជុំវិញការរស់នៅ ..... ទំព័រទី ១៣

១.២.១ បរិយាកាសទូទៅនៅតាមសំណង់បន្ទប់ជួល ..... ទំព័រទី ១៣

១.២.២ គុណភាពចំណីអាហារ ..... ទំព័រទី ១៣

១.២.៣ ទឹកប្រើប្រាស់ និងបរិភោគ ..... ទំព័រទី ១៤

១.២.៤ ការលាងសម្អាតដៃ ..... ទំព័រទី ១៥

១.២.៥ ការប្រើប្រាស់បង្គន់អនាម័យ គុណភាព និងសុវត្ថិភាព ..... ទំព័រទី ១៦

១.២.៦ កាកសំណល់ និងប្រព័ន្ធលូ ..... ទំព័រទី ១៧

១.២.៦.១ ការទុកសំរាម និងថ្លៃសេវា ..... ទំព័រទី ១៧

១.២.៦.២ ប្រព័ន្ធលូ ..... ទំព័រទី ១៨

**ផ្នែកទី២៖ សន្តិសុខ និងសុវត្ថិភាព**

២.១ ស្ថានភាពសន្តិសុខ ..... ទំព័រទី ២១

២.១.១ ករណីលួចនៅតាមបន្ទប់ជួល ..... ទំព័រទី ២១

២.១.២ ករណីគាស់នៅតាមបន្ទប់ជួល ..... ទំព័រទី ២៣

២.១.៣ ការរាយការណ៍ ..... ទំព័រទី ២៤

២.១.៤ ភ្លើងបំភ្លឺច្រកចូលបន្ទប់ជួល ..... ទំព័រទី ២៥

២.២ ស្ថានភាពសុវត្ថិភាព ..... ទំព័រទី ២៥

២.២.១ ក្មេងទំនើង ..... ទំព័រទី ២៥

២.២.២ ការប្រើប្រាស់ ឬជួញដូរគ្រឿងញៀន ..... ទំព័រទី ២៦

២.២.៣ ការលេងល្បែងស៊ីសង ..... ទំព័រទី ២៧

២.២.៤ ការបៀតបៀនកេរ្តិ៍ខ្មាស ..... ទំព័រទី ២៧

២.២.៥ ការអន្តរាគមន៍ពីអាជ្ញាធរក្នុងតំបន់ ..... ទំព័រទី ២៨
២.២.៦ ប្រជាការពារភូមិ និងប៉ុស្តិ៍ឃាម ..... ទំព័រទី ២៨

**ផ្នែកទី៣៖ ស្ថានភាពបន្ទប់រស់នៅ**
៣.១ ស្តង់ដារបន្ទប់ជួល និងបរិក្ខា ..... ទំព័រទី ៣៣
៣.១.១ ស្ថានភាពជុំវិញបន្ទប់ជួល ..... ទំព័រទី ៣៣
៣.១.២ ទំហំបន្ទប់ជួល ..... ទំព័រទី ៣៤
៣.១.៣ តម្លៃបន្ទប់ជួល ..... ទំព័រទី ៣៥
៣.១.៤ បទបញ្ជាផ្ទៃក្នុងបន្ទប់ជួល ..... ទំព័រទី ៣៦
៣.១.៥ កិច្ចសន្យាបន្ទប់ជួល ..... ទំព័រទី ៣៧
៣.១.៦ សេវាកម្មទឹក ..... ទំព័រទី ៣៨
៣.១.៧ សេវាកម្មអគ្គីសនី ..... ទំព័រទី ៣៩
៣.១.៨ បរិក្ខាបន្ទប់ជួល និងការជួសជុលបន្ទប់ជួល ..... ទំព័រទី ៤០
៣.១.៩ បំពង់ពន្លត់អគ្គីភ័យក្នុងអគារ ..... ទំព័រទី ៤០

**មតិយោបល់ និងអនុសាសន៍** ..... ទំព័រទី ៤២

**ជញ្ជាំងផ្ទុះធ្លាយ** ..... ទំព័រទី ៤៥

**ឯកសារយោង** ..... ទំព័រទី ៥១

**ឧបសម្ព័ន្ធ** ..... ទំព័រទី ៥២

# សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះ បានចាប់ផ្តើមនៅខែសីហា ឆ្នាំ២០១៦ បន្ទាប់ពីមានការព្រមព្រៀងលើគំនិត និងគោលបំណងក្នុងចំណោមបុគ្គលិក អ្នកចងក្រង និងកម្មការិនីកម្មករនៃសមាគមមណ្ឌលព័ត៌មានកម្មករ បូករួមនិងការពិភាក្សាជាមួយដៃគូរបស់យើងរួមមានអង្គការ Focus on The Global South និង WaterAid ដែលបានគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ការសិក្សាស្រាវជ្រាវនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះកម្មការិនី កម្មករដែលបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់បទសម្ភាសន៍ និងពិភាក្សាក្រុមដោយអត់ធ្មត់ និងបានពន្យល់រៀបរាប់ពីដំណើរជីវិត និងស្ថានភាពរស់នៅក្នុងប្លុកបន្ទប់ជួលរបស់ខ្លួន។ កម្មការិនី កម្មករមានឆន្ទៈក្នុងការនិយាយចេញដោយបើកចំហ និងស្មោះត្រង់ពីបទពិសោធនៃការរស់នៅក្នុងបរិយាកាសដែលគ្មានសុវត្ថិភាព និងផាសុកភាព។

យើងសូមថ្លែងអំណរគុណជាពិសេសដល់ក្រុមការងារស្រាវជ្រាវដែលជាកម្មការិនី កម្មករចំនួន ៣៨នាក់ ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សានេះ ចាប់តាំងពីការកំណត់របៀបធ្វើបង្កើតកំរងសំណួរ ចុះប្រមូលទិន្នន័យ ព័ត៌មាន ការវិភាគ រហូតដល់ការធ្វើរបាយការណ៍បោះពុម្ពផ្សាយ។ ទោះបីជាក្រុមស្រាវជ្រាវសុទ្ធតែជាកម្មការិនី កម្មករកាត់ដេរដែលធ្វើការច្រើនម៉ោងក្នុងរោងចក្រពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ក្តី ពួកគាត់មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសិក្សាស្រាវជ្រាវនេះ ពីព្រោះពួកគាត់ចង់រៀនសូត្រពីរបៀបនៃការស្រាវជ្រាវ មានភាពជាម្ចាស់នៃដំណើរការ និងចូលរួមចំណែកធ្វើឲ្យមានការផ្លាស់ប្តូរនូវស្ថានភាពរស់នៅរបស់ពួកគាត់ និងកម្មការិនី កម្មករដទៃទៀត។

យើងក៏សូមថ្លែងអំណរគុណចំពោះក្រុមការងារនៃសមាគមមណ្ឌលព័ត៌មានកម្មករ និងអ្នកបច្ចេកទេស ដែលធ្វើការងារមិនខ្លាចនឿយហត់ក្នុងការគាំទ្រ និងសម្របសម្រួលដំណើរការនៃការសិក្សានេះជាមួយក្រុមស្រាវជ្រាវ និងកម្មការិនី កម្មករ ដោយផ្តល់នូវបច្ចេកទេស និងបំពេញបន្ថែមសមត្ថភាពដែលពួកគាត់ត្រូវការ។ ក្រុមការងារសមាគមមណ្ឌលព័ត៌មានកម្មករ និងអ្នកបច្ចេកទេស បានធ្វើតាមគោលការណ៍នៃដំណើរការសិក្សាដោយឥរិយាបថចែករំលែក និងស្តាប់ដោយយកចិត្តទុកដាក់។ ប្រសិនបើគ្មានក្រុមការងារបែបនេះទេ ការសិក្សានេះនឹងមិនអាចធ្វើទៅបាន ហើយសម្លេង និងបទពិសោធរបស់កម្មការិនី កម្មករក៏នឹងមិនត្រូវបានកត់ត្រាទុកនោះដែរ។

# សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ១៩៩៤ ដែលរោងចក្រកាត់ដេរបានបង្កើតឡើងដំបូងក្នុងប្រទេសកម្ពុជាមក វិស័យឧស្សាហកម្មនេះបានលូតលាស់យ៉ាងឆាប់រហ័ស។ វិស័យនេះជាសកម្មភាពឧស្សាហកម្មដ៏ចំបងមួយនៅកម្ពុជា ព្រមទាំងជាប្រភពចំនូលដ៏សំខាន់នៃការនាំចេញទំនិញផងដែរ។

រូបភាពទី **7** ៖ សមាសភាពនៃការនាំចេញទំនិញពីកម្ពុជា ឆ្នាំ **2010** និងឆ្នាំ **2015**




*ប្រភព: កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា ព្រឹត្តិប័ត្រវិស័យកាត់ដេរសម្លៀកបំពាក់*

*និងស្បែកជើងកម្ពុជាលេខ ៣ ខែមីនា ឆ្នាំ២០១៦*

ឧស្សាហកម្មវាយនភណ្ឌកាត់ដេរ បន្តជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជាអស់រយៈពេលជិត២ទស្សវត្សដែលនៅឆ្នាំ២០១៥ ការនាំចេញមានតម្លៃ ៦,២៧៩ លានដុល្លារអាមេរិក ហើយរួមចំណែក ១០ភាគរយទៅក្នុងផលទុនជាតិសរុបជារៀងរាល់ឆ្នាំ។ នៅកម្ពុជាមានរោងចក្រចំនួនប្រមាណ ៦៥៥ រោងចក្រ (ឆ្នាំ២០១៥) និងមានកម្មការិនីកម្មករកំពុងបម្រើការប្រមាណ ៧០ម៉ឺននាក់ ដែលភាគច្រើននៃពួកគេ (ប្រហែល ៩០ភាគរយ) ជាស្ត្រីនិងចំណាកស្រុកមកពីតំបន់ជនបទ។

លក្ខខណ្ឌសេដ្ឋកិច្ចបានជំរុញឲ្យក្មេងស្រីនៅតំបន់ជនបទនៃប្រទេសកម្ពុជា បោះបង់ចោលការសិក្សានៅវ័យក្មេងនាំគ្នាចំណាកស្រុកមកទីក្រុង ហើយទទួលបានការងារនៅតាមរោងចក្រកាត់ដេរ។ ពួកគេភាគច្រើនដែលបានចាកចេញពីផ្ទះមកមានអាយុត្រឹមតែពី ១៨ ទៅ ២៥ ឆ្នាំតែប៉ុណ្ណោះ។ ពួកគេបានផ្លាស់ទីលំនៅពីទីជនបទក្នុងក្តីសង្ឃឹមមកស្វែងរកឱកាសការងារប្រសើរសម្រាប់ខ្លួន និងដើម្បី

ផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេ។ ផ្ទុយទៅវិញពួកគេបែរជាជួបការលំបាកនៅកន្លែងការងារ និងបញ្ហាក្នុងជីវិតរស់នៅ។ កម្មករកម្មការិនីទាំងនេះធ្វើការពី១០ ទៅ១២ម៉ោងក្នុងមួយថ្ងៃ និង៦ថ្ងៃក្នុងមួយសប្តាហ៍។ អំឡុងពីរបីឆ្នាំមុន ពួកគេទទួលប្រាក់ឈ្នួលអប្បរមាតែ ៨០ ដុល្លារប៉ុណ្ណោះក្នុងមួយខែ។

ចាប់ពីពេលដែលរាជរដ្ឋាភិបាលបានបង្កើតគណកម្មការចរចាត្រីភាគី អំពីប្រាក់ឈ្នួលអប្បបរមានៅឆ្នាំ២០១៤មក ប្រាក់ឈ្នួលបានកើនឡើងជារៀងរាល់ឆ្នាំ ដែលប្រាក់ឈ្នួលអប្បបរមាទទួលបានចំនួន ១០០ដុល្លារអាមេរិកនៅឆ្នាំ២០១៤ ១២៨ដុល្លារនៅឆ្នាំ២០១៥ ១៤០ដុល្លារនៅឆ្នាំ២០១៦ ហើយឆ្នាំនេះ ២០១៧ ប្រាក់ឈ្នួលបានកើនដល់ ១៥៣ដុល្លារ។ ទន្ទឹមនឹងនេះដែរ នៅឆ្នាំ២០១៥ រដ្ឋាភិបាលបានអនុម័តច្បាប់ភតិសន្យាពិសេស(ច្បាប់បន្ទប់ជួល) និងសេចក្តីប្រកាសព័ត៌មានពីការទទួលបានការតបណ្តាញអគ្គិសនីរដ្ឋសម្រាប់កម្មកា រិនីកម្មករ ហើយនៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលក៏បានពង្រីកគោលនយោបាយបេឡាជាតិរបបសន្តិសុខសង្គម ដែលផ្តោតលើហានិភ័យនៅកន្លែងធ្វើការបន្ថែមឲ្យមានការធានារ៉ាប់រងសុខភាពសម្រាប់កម្មការិនី កម្មករ។ ទោះបីជាយ៉ាងណាក្តី លក្ខខណ្ឌរស់នៅរបស់កម្មការិនី កម្មករនៅមិនទាន់មានភាពប្រសើរឡើងនៅឡើយ។ ការចំណាយទៅលើការរស់នៅដែលរួមមានថ្លៃបន្ទប់ជួល និងសេវាទឹក ភ្លើង កើនឡើងមិនឈប់ ហើយកម្មការិនីភាគច្រើនកំពុងរស់នៅក្នុងបរិយាកាសដែលគ្មានសុវត្ថិភាព និងផាសុកភាព។

## មូលហេតុនៃការសិក្សា

នៅខែមីនា ឆ្នាំ២០១៥ សម្ព័ន្ធបងប្អូនស្រីដែលក្នុងនោះសមាគមមណ្ឌលព័ត៌មានកម្មករជាស្ថាប័ន សមាជិកបានដាក់ចេញនូវយុទ្ធនាការមួយស្តីពី «***សិទ្ធិស្ត្រីក្នុងការទទួលបានសេវាសង្គមជាមូលដ្ឋាន***» ក្នុងគោលបំណងធ្វើការតស៊ូមតិសម្រាប់កម្មការិនីកម្មកររោងចក្រ និងស្ត្រីប្រកបរបរផ្លូវភេទឲ្យទទួលបានជម្រក និងសេវាទឹកភ្លើង សេវាថែទាំសុខភាព និងសន្តិសុខ សុវត្ថិភាព តាមរយៈការបង្កើតឲ្យមានគោលនយោបាយប្រជាជន។ ចាប់តាំងពីយុទ្ធនាការបានដំណើរការមក មណ្ឌលព័ត៌មានកម្មករបានរៀបចំកិច្ចពិគ្រោះយោបល់នៅក្នុងមូលដ្ឋានជាច្រើនដង នៅមណ្ឌលសំចតជាមួយកម្មការិនីកម្មកររោងចក្រ។ កិច្ចពិគ្រោះយោបល់ទាំងនោះផ្តោតលើការវិភាគពីស្ថានភាពរស់នៅរបស់កម្មករ ដោយឆ្លុះបញ្ចាំងទៅលើក្របខណ្ឌច្បាប់ និងគោលនយោបាយដែលរួមមាន ច្បាប់ភតិសន្យាពិសេស (ច្បាប់បន្ទប់ជួល) សេចក្តីប្រកាសព័ត៌មានស្តីពីវិធានការបន្តសម្រាប់ផ្ទះជួលឬបន្ទប់ជួល ក្នុងតំបន់ចែកចាយផ្ទាល់របស់អគ្គិសនីកម្ពុជានៅរាជធានីភ្នំពេញ និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព។ លទ្ធផល

បានពីការវិភាគ និងពិគ្រោះយោបល់ត្រូវបានចងក្រង និងអភិវឌ្ឍទៅជាគោលនយោបាយប្រជាជន ដែលបានដាក់បញ្ចូលការទាមទារ និងអនុសាសន៍ជាដំណោះស្រាយសម្រាប់អ្នកពាក់ព័ន្ធ។

ខណៈដែលកិច្ចពិគ្រោះយោបល់បានបញ្ចប់ ហើយផែនការប្រតិបត្តិកំពុងតែអភិវឌ្ឍ មណ្ឌលព័ត៌មានកម្មករបានចាប់ផ្តើមការសិក្សានេះដោយមានគោលបំណងដូចខាងក្រោម៖

- ធ្វើឲ្យមានការយល់ដឹងកាន់តែច្បាស់ពីលក្ខខណ្ឌរស់នៅ និងការទទួលបានសេវាសង្គមជាមូលដ្ឋានរបស់កម្មការិនីកម្មករ
- ធ្វើឲ្យមានការយល់ដឹងទូលំទូលាយពីផលប៉ះពាល់នៃលក្ខខណ្ឌរស់នៅទៅលើការអភិវឌ្ឍ និងជីវិតរស់នៅប្រកបដោយភាពថ្លៃថ្នូររបស់កម្មការិនីកម្មកររោងចក្រ
- បោះពុម្ពផ្សាយ និងប្រើប្រាស់ទិន្នន័យដែលប្រមូលបានសម្រាប់ធ្វើការតស៊ូមតិឲ្យមានភាពប្រសើរឡើងទៅលើសិទ្ធិ និងលក្ខខណ្ឌរស់នៅរបស់កម្មការិនីកម្មករ

## វិធីសាស្ត្រនៃការសិក្សា

ការសិក្សានេះគឺជាការសិក្សាបែបគុណភាព ដែលមានបំពេញបន្ថែមនូវការស្ទង់មតិបែបបរិមាណផងដែរ។ វិធីសាស្ត្រសម្រាប់ការស្រាវជ្រាវដែលត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- កម្មការិនី កម្មករសកម្មមកពីមណ្ឌលសំចតចំនួន ៦ ត្រូវបានចងក្រងជាក្រុមស្រាវជ្រាវ (ប្រមាណ៣៨នាក់) និងទទួលការបណ្តុះបណ្តាលពីការប្រមូលទិន្នន័យ និងចូលរួមក្នុងដំណើរការទាំងមូលនៃការសិក្សានេះ
- ការសិក្សានេះបានប្រើគោលការណ៍បែបគុណភាពដោយសម្ភាសន៍ និងពិភាក្សាក្រុម រួមទាំងមានកម្រងរូបភាព។ គោលការណ៍នេះបានអនុញ្ញាតឲ្យក្រុមស្រាវជ្រាវមានឱកាសធ្វើការពិភាក្សាមិនផ្លូវការជាមួយក្រុមកម្មការិនី កម្មករ ដូចគ្នានិងក្នុងគោលបំណងពង្រឹងនូវទំនាក់ទំនងរបស់ពួកគេ
- ការសម្ភាសដំបូងធ្វើឡើងជាមួយកម្មការិនីកម្មករចំនួន៧៥នាក់ និងបន្ទាប់មកទៀតមានការពិភាក្សាក្រុមជាមួយកម្មករផ្សេងទៀតចំនួន៩០នាក់។ ការសិក្សាដែលជ្រើសយកដំណើរការបែបនេះ គឺដើម្បីធានាថា ក្រុមស្រាវជ្រាវមានពេលវេលាក្នុងការពិនិត្យលទ្ធផលពីការសម្ភាសឡើងវិញ និងបំពេញនូវចន្លោះខ្វះខាតសម្រាប់ការស្វែងយល់ទៅក្នុងការពិភាក្សាក្រុម។ ការឆ្លុះបញ្ចាំងក៏ត្រូវបានប្រើប្រាស់ផងដែរនៅរាល់ជំហានក្នុងដំណើរការ ទើបក្រុមស្រាវជ្រាវអាចរៀនពីបទពិសោធ និងកែតម្រូវសម្រាប់ដំណើរការនិងការពិភាក្សាបន្តបន្ទាប់ទៀត។

- លទ្ធផលពីការប្រមូលទិន្នន័យ ត្រូវបានយកមកពិគ្រោះយោបល់ និងវិភាគឆ្លុះបញ្ចាំងទៅនឹងគោលនយោបាយ រួមទាំងសេចក្តីជូនដំណឹងផ្សេងៗដោយក្រុមស្រាវជ្រាវផ្ទាល់
- កម្មការិនីមួយចំនួនត្រូវបានពង្រឹងបន្ថែមពីរបៀបថតរូប និងថតវីដេអូដែលរូបភាពទាំងនោះបង្ហាញពីតថភាព និងរឿងរ៉ាវអំពីស្ថានភាពរស់នៅ និងការងាររបស់ពួកគាត់

មណ្ឌលសំចតដែលបានកំណត់យកក្នុងការសិក្សា ស្ថិតនៅក្នុងតំបន់ចំនួនបីរួមមានតំបន់ចាក់អង្រែក្រោម ពោធិ៍សែនជ័យ និងទឹកថ្លា។ រីឯអគារបន្ទប់ជួលដែលត្រូវបានជ្រើសរើស គឺជាអគារដែលមានបន្ទប់ជួលចន្លោះពី ៥០ ទៅ ៣០០ បន្ទប់ ហើយមានកម្មការិនីកម្មករស្នាក់នៅតិចបំផុតពី ២ទៅ ៣នាក់ក្នុងមួយបន្ទប់។ កម្មការិនីកម្មករដែលត្រូវបានជ្រើសរើសក្នុងការសិក្សានេះមានចំនួន ១៦៥ នាក់។ កម្មការិនីកម្មករទាំងនោះត្រូវបានជ្រើសរើសពីអគារបន្ទប់ជួល និងជាន់ខុសៗគ្នានៅតំបន់គោលដៅទាំងបី។

# ផ្នែកទី១

## ស្ថានភាពសុខភាព និងអនាម័យ

## ១.១ ស្ថានភាពសុខភាព និងអនាម័យ

### ១.១.១ ស្ថានភាពសុខភាព

កម្មការិនីកម្មករកាត់ដេរ ដែលកំពុងបំពេញការងារយ៉ាងនឿយហត់នៅក្នុងរោងចក្រកំពុងជួប បញ្ហាសុខភាព ដោយសារតែការធ្វើការច្រើនម៉ោង (ពី៨ម៉ោងទៅ១២ម៉ោងក្នុងមួយថ្ងៃ) នៅក្នុងរោងចក្រ ដែលមានបរិយាកាស ហប់ ក្តៅ ធូលី បូករួមការស្រូបក្លិនពីកំទេចក្រណាត់។ បន្ថែមពីទទួលទានចំណីអាហារមិនគ្រប់គ្រាន់ ខ្វះជីវជាតិ គ្មានអនាម័យ ជាផ្នែកមួយបណ្តាលឲ្យស្ថានភាពសុខភាព កម្មការិនីកម្មករ ទន់ខ្សោយ ហើយប្រឈមនឹងជំងឺនានាដូចជា វិលមុខ អស់កម្លាំង ឈឺក្បាល ស្រវាំងភ្នែក ឈឺក្រពះ និងពោះវៀនជាដើម។ កម្មការិនីពោធិ៍សែនជ័យបញ្ជាក់ថា៖

**ស្ថានភាពសុខភាពឆ្នាំ២០១៦**




គិតជាភាគរយក្នុងចំណោម៧៥នាក់

«*សុខភាពខ្ញុំខ្សោយជាងមុន ទន់ដៃ ទន់ជើង អស់កម្លាំង ហើយធ្លាក់ស*»។

តាមរយៈការសម្ភាសកម្មការិនី កម្មករ មានកម្មការិនី កម្មករ ៦០ភាគរយ បានឲ្យដឹងថា សុខភាពរបស់ពួកគាត់បានចុះខ្សោយនៅរយៈពេលមួយឆ្នាំក្រោយនេះ ស្របពេលដែលកម្មការិនី ៣៤ភាគរយ មានសុខភាពធម្មតា ហើយ ៦ភាគរយ មានសុខភាពទ្រុឌទ្រោម។ កម្មការិនីនៅតំបន់ចាក់អង្រែក្រោម លើកឡើងថា៖ ***«ជាទូទៅឈឺក្រពះ ពោះវៀន និងឈឺសន្លាក់ដៃជើង ហើយលេបថ្នាំបាត់តែមួយភ្លែតៗ ក្រោយមកឈឺដដែល»***។ កម្មការិនីម្នាក់ទៀតបន្ថែមថា៖ ***«ខ្ញុំឈឺក្រពះ ពោះវៀន និងរលាកប្លោកនោម»*** ។

ស្ថានភាពសុខភាពរបស់កម្មការិនី កម្មករ បានចុះខ្សោយពីមួយថ្ងៃទៅមួយថ្ងៃដោយសារស្ថានភាពការងារនៅក្នុងរោងចក្រមានការកំណត់ចំនួនទិន្នផលកើនឡើង ការងារជាប្រព័ន្ធខ្សែទឹកហូរដែលធ្វើឲ្យកម្មការិនី កម្មករខិតខំប្រឹងប្រែងធ្វើការទ្វេដង។ រីឯចំណីអាហារបរិភោគទៀតសោត ភាគច្រើនមានសារជាតុគីមី « ***ចំណីអាហារហូបរាល់ថ្ងៃគីមីទាំងអស់ ទាំងត្រី សាច់ បន្លែអីសុទ្ធតែជាតិគីមី***»។

### ១.១.២ ការប្រើប្រាស់សេវាសុខភាព និងតម្លៃព្យាបាល

កម្មការិនី កម្មករ ភាគច្រើនប្រើប្រាស់សេវាសុខភាពនៅតាមគ្លីនិកឯកជន ឬឱសថស្ថាននានា ដែលនៅក្បែរតំបន់រស់នៅរបស់ពួកគាត់ជាជាងប្រើប្រាស់សេវាសាធារណៈរបស់រដ្ឋ។ ក្នុងចំណោម កម្មករ៧៥នាក់ មានកម្មការិនី កម្មករប្រមាណជា ៣៩,៨ភាគរយ ប្រើប្រាស់សេវាសុខភាពនៅគ្លីនិកឯកជន ៣៧,៣ភាគរយប្រើប្រាស់នៅឱសថស្ថាន ខណៈដែលភាគរយនៃការប្រើប្រាស់នៅមន្ទីរពេទ្យរដ្ឋ

មានត្រឹមតែ ៦ភាគរយ និងនៅមណ្ឌលសុខភាពមាន ៩,៦ភាគរយ ប៉ុណ្ណោះ។ ជាមធ្យមកម្មការិនីកម្មករបានចំណាយប្រាក់ប្រមាណ ២ម៉ឺនរៀល ក្នុងការទៅព្យាបាលសុខភាពនៅមន្ទីរពេទ្យឯកជនក្នុងមួយលើក តែបើករណីធ្ងន់ធ្ងរគឺចំណាយលើសពី១០ម៉ឺនរៀល។ កម្មការិនីកម្មករ (៥២,២ភាគរយ) បានទទួលស្គាល់ថាតម្លៃសេវានៅគ្លីនិកគឺថ្លៃជាងនៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាពរបស់រដ្ឋ។ កម្មការិនីនៅតំបន់ចាក់អង្រែក្រោម៖ *«ខ្ញុំចំណាយអស់ ៩ម៉ឺន ទាំងឆ្លុះអេកូ ហើយថ្នាំអស់ ៧ម៉ឺន ហើយខ្ញុំគិតថា*

## ការប្រើប្រាស់សេវាព្យាបាលនៅពេលឈឺ

| | ការឆ្លើយតប | |
|---|---|---|
| | ចំនួន | ភាគរយ |
| គ្លីនិកឯកជន | 33 | 39.8% |
| មណ្ឌលសុខភាព | 8 | 9.6% |
| មន្ទីរពេទ្យ | 5 | 6.0% |
| ឱសថស្ថាន | 31 | 37.3% |
| ផ្សេងៗ | 6 | 7.2% |
| សរុប | 83 | 100% |

គិតជាភាគរយក្នុងចំណោម៧៥នាក់

*ថ្នាំថ្លៃដែរ ណាមួយលេបបានជាតែមួយភ្លែតៗ ហើយឈឺដដែល*»។ ហេតុដែលប្រើប្រាស់គ្លីនិកឯកជនព្រោះផ្តល់សេវាឆាប់រហ័ស គ្រូពេទ្យរួសរាយរាក់ទាក់ និងមានភាពងាយស្រួលជាមន្ទីរពេទ្យរដ្ឋ ឬមណ្ឌលសុខភាពដែលមានទីតាំងនៅឆ្ងាយ ហើយសេវាកម្មយឺត (ចំណាយពេលច្រើន) គ្រូពេទ្យមិនសូវរាក់ទាក់ និងព្យាបាលមិនបានដិតដល់។ កម្មការិនីនៅតំបន់ចាក់អង្រែក្រោមនិយាយថា៖ *«ខ្ញុំគិតថាទៅពេទ្យរដ្ឋវាយូរហើយសំដីពេទ្យរដ្ឋខ្លះមិនល្អ ហើយថ្នាំហូបដូចជាមិនសូវត្រូវនឹងជំងឺរបស់យើង ប៉ុន្តែបើយើងទៅពេទ្យឯកជនគឺលឿន ហើយសំដីស្រួលនិយាយគ្នា គ្រាន់តែថាវាអស់លុយច្រើនបន្តិច»*។ កម្មការិនីម្នាក់បន្ថែមថា៖ *«តែពេទ្យឯកជនខ្លះក៏មិនសូវយកចិត្តទុកដាក់ដែរ ជាពិសេសអ្នកណាដែលខ្វះលុយ»*។ ចំណែកកម្មការិនីតំបន់ពោធិ៍សែនជ័យ *«ពេទ្យរដ្ឋនៅឆ្ងាយ ខាតពេលវេលា មិនសូវយកចិត្តទុកដាក់ អាកប្បកិរិយាមិនសមរម្យ មើលថែទាំមិនដិតដល់ ហើយបើជិះម៉ូតូទៅក៏ចំណាយអស់ច្រើនដែរ »*។

### ១.២ អនាម័យជុំវិញការរស់នៅ

#### ១.២.១ បរិយាកាសទូទៅនៅតាមសំណង់បន្ទប់ជួល

កម្មការិនីកម្មករភាគច្រើនរស់នៅតាមប្លុកបន្ទប់ជួលតូចចង្អៀត និងគ្មានស្តង់ដារដែលមានទីតាំងនៅក្បែររោងចក្រដែលពួកគេធ្វើការ។ នៅតាមតំបន់បន្ទប់ជួលមានប្រភពពន្លឺពីរសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃគឺ ពន្លឺអគ្គិសនី និងពន្លឺព្រះអាទិត្យ។ តាមរយៈការស្រាវជ្រាវបន្ទប់កម្មករ ៦៥,៣ភាគរយ មានពន្លឺគ្រប់គ្រាន់នៅក្នុងបន្ទប់ស្នាក់នៅ និងបន្ទប់ ៣៤,៧ភាគរយ មិនមានពន្លឺគ្រប់គ្រាន់នៅក្នុងបន្ទប់ឡើយ។ ពួកគាត់ភាគច្រើនប្រើប្រាស់ពន្លឺចង្កៀងអគ្គិសនី ដើម្បីឲ្យមានពន្លឺគ្រប់គ្រាន់ក្នុងការរស់នៅប្រចាំថ្ងៃ។

បរិយាកាសបន្ទប់ជួលមានលក្ខណៈ ក្តៅ ហប់ ហើយនៅតំបន់ខ្លះមានសំរាមជុំវិញប្លុកជួលខ្លះជះក្លិនស្អុយដល់អ្នករស់នៅក្នុងបន្ទប់។ កម្មការិនីនៅតំបន់ទឹកថ្លា៖ «*និយាយទៅអត់មានខ្យល់ចេញចូលទេ គ្រាន់តែចូលផ្ទះគឺបើកកង្ហា បើអត់ប្រើគឺដេកអត់បានទេវាក្តៅហប់ហ្មង អត់ដូចផ្ទះគេទេដែលចូលមិនបាច់ប្រើកង្ហា ប៉ុន្តែធ្វើម៉េចយើងវាទ័លហើយយើងទ្រាំ ហើយបើនៅកន្លែងផ្សេងទៀតវាថ្លៃឈ្នួលផ្ទះក៏ថ្លៃ ហើយប្រាក់យើងប៉ុណ្ណឹងវាមិនសមរម្យទេ*»។ ម្ចាស់បន្ទប់ជួលភាគច្រើនតែងសង់បន្ទប់ជួលលើផ្ទៃដីធំទូលាយ ប៉ុន្តែពួកគាត់បានទុកចន្លោះសម្រាប់ធ្វើដំណើរតូចចង្អៀត។ ម្យ៉ាងវិញទៀតអ្នកជួលភាគច្រើនដែលជាកម្មការិនី កម្មកររោងចក្រ ពួកគាត់សម្រាកពីការងារនៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យដូច្នេះថ្ងៃទាំងនេះជាឱកាសសម្រាប់ពួកគាត់បោកសម្លៀកបំពាក់ មួយវិញទៀតបោកសម្លៀកបំពាក់ថ្ងៃឈប់សម្រាក គឺធានាថាខោអាវរបស់គាត់គ្មានចោរលួច។ អាស្រ័យហេតុនេះមានកម្មការិនី កម្មករ ៦០ ភាគរយ បានឆ្លើយថា ពួកគាត់គ្មានកន្លែងហាលសម្លៀកបំពាក់សមរម្យទេ។ កម្មការិនីនៅតំបន់ពោធិ៍សែនជ័យ៖ «*កន្លែងហាលខោអាវខាងខ្ញុំ អត់សមរម្យទេ ព្រោះត្រូវហាលនៅមុខបន្ទប់ ហើយកន្លែងក៏តូចចង្អៀតខោអាវក៏អត់ត្រូវពន្លឺថ្ងៃទៀត*»។

#### ១.២.២ គុណភាពចំណីអាហារ

ក្រៅពីការរស់នៅក្នុងស្ថានភាពបន្ទប់ជួលដែលគ្មានស្តង់ដារ និងគ្មានសុវត្ថិភាព ការទទួលទានអាហារ និងចំណីរបស់កម្មករមានការប្រឈមខ្ពស់ទៅនឹងបញ្ហាអនាម័យ «*ខ្ញុំជួបផ្ទាល់នៅពេលញ៉ាំបាយ គឺនៅក្នុងសម្លមានក្រចកដៃ ក្រចកជើង ... ចំណែកខ្ញុំវិញ គឺជួបសក់មួយដុំនៅក្នុងសម្លនោះ ពេលនោះខ្ញុំហូប*



គិតជាភាគរយក្នុងចំណោម៧៥នាក់

*មិនកើតទេ គឺឆ្អួតតែម្តង»*។ ការញ៉ាំអាហារដែលចំណាយតិច និងងាយស្រួលរកទិញ ហើយមានតម្លៃថោក គឺជាអាហារដែលចម្អិនស្រាប់។ យ៉ាងណាមិញ ការចម្អិនអាហារដោយខ្លួនឯង គឺត្រូវចំណាយពេលវេលាច្រើន ជាពិសេសពេលថ្ងៃត្រង់ ព្រោះពេលវេលាសម្រាកមានត្រឹមតែមួយម៉ោង ឬមួយម៉ោងកន្លះប៉ុណ្ណោះ ហើយត្រូវចំណាយថវិកាច្រើន បើប្រៀបធៀបទៅនឹងម្ហូបអាហារដែលចម្អិនស្រាប់។ កម្មការិនីតំបន់ពោធិ៍សែនជ័យបញ្ជាក់ថា៖ *«អត់ជម្រើសព្រោះគ្មានលុយ ពេលវេលាតិច មិនសូវចំណាយកម្លាំង»*។ ទោះជាយ៉ាងនេះក៏ដោយ ក្នុងចំណោមកម្មករដែលបានសម្ភាសន៍មានកម្មករ ៧៤,៣ភាគរយបានអះអាងថា ពួកគាត់ទទួលទានអាហារដែលមានអនាម័យ[1]។ មូលហេតុដែលគាត់យល់ថា គាត់ទទួលទានអាហារមានអនាម័យពីព្រោះគាត់ចម្អិនអាហារដោយខ្លួនឯង។ កម្មការិនីនៅតំបន់ទឹកថ្លា៖ «*ខ្ញុំគិតថា នៅពេលដែលយើងធ្វើម្ហូបឲ្យមានអនាម័យគឺល្អ ខ្ញុំទិញបន្លែធ្វើម្ហូបខ្លួនឯង ព្រោះម្ហូបទិញស្រាប់មិនល្អទេ មុនពេលលាងបន្លែត្រីសាច់អីហ្នឹង ខ្ញុំដាក់អំបិលបន្តិច ហើយត្រាំវាួចលាងឲ្យស្អាត*»។

### ១.២.៣ ទឹកប្រើប្រាស់ និងបរិភោគ

ទឹកគឺជាធាតុដ៏សំខាន់ក្នុងការទ្រទ្រង់សុខភាពប្រជាជនទូទៅ។ ផ្អែកតាមការសិក្សាស្រាវជ្រាវ និងជួបសម្ភាសជាមួយកម្មការិនី កម្មករដែលរស់នៅតាមបន្ទប់ជួលនៅក្នុងទីក្រុងភ្នំពេញសព្វថ្ងៃនេះ ពួកគាត់ប្រើប្រាស់ទឹកមកពីប្រភពផ្សេងៗគ្នាសម្រាប់បរិភោគ និងប្រើប្រាស់ប្រចាំថ្ងៃដូចជា ទឹកមកពីក្បាលរ៉ូប៊ីណេ (៨៥,១ភាគរយ) ទឹកទន្លេ (១,៥ភាគរយ) និងប្រភពផ្សេងៗទៀត (១៣,៤ភាគរយ)។




ដោយសារតែទំហំ និងស្ថានភាពបន្ទប់ជួលខុសគ្នាពីប្លុកមួយទៅប្លុកមួយ ពីតំបន់មួយទៅតំបន់មួយ អាស្រ័យទៅតាមការសាងសង់របស់ម្ចាស់ផ្ទះជួលហេតុនេះទីធ្លា និងទំហំបន្ទប់គឺជាបញ្ហាចោទសម្រាប់កម្មការិនី កម្មករក្នុងការតំកល់ទឹកទុកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីធានានូវសុវត្ថិភាព និងអនាម័យ។ កម្មការិនី កម្មករ ភាគច្រើនប្រើប្រាស់ទឹកផ្ទាល់ពីក្បាលរ៉ូប៊ីណេ (៧៦,៤ភាគរយ) ខ្លះរក្សាទុកក្នុងពាងដោយមានគម្រប (៨,៣ភាគរយ) ខ្លះទុកនៅក្នុងពាងដោយគ្មានគម្រប (៤,២ភាគរយ) រក្សាទុកក្នុងធុង (២,៨ភាគរយ) និងផ្សេងៗទៀតមាន (៨,៣ភាគរយ)។ ចំណែកឯការទទួលទានទឹកវិញកម្មការិនី កម្មករញ៉ាំទឹកសុទ្ធ

---

[1] កម្មករឲ្យនិយមន័យអាហារដែលមានអនាម័យថាជាអាហារដែលគាត់ធ្វើខ្លួនឯង និងលាងសម្អាតបានត្រឹមត្រូវ

(៣៣,៨ភាគរយ) ទឹកដាំឆ្អិន (២៥,៤ភាគរយ) ទឹកមិនដាំពុះ (២១,១ភាគរយ) និងប្រភេទទឹកចេញពីធុងចំរោះ (១៩,៧ភាគរយ) ។ សម្រាប់កម្មការិនី កម្មករ នៅតំបន់ចាក់អង្រែក្រោមភាគច្រើនពួកគាត់ប្រើប្រាស់ទឹកអណ្តូង ហើយទឹកខ្លះមានជាតិកំបោរ *«ទឹកដែលងូតរាល់ថ្ងៃគឺទឹកអណ្តូង ហើយទឹកអណ្តូងហ្នឹងគ្រាន់តែត្រាំផ្ទាំងទៅជាកក ជាប់កំបោរ»*។

ទន្ទឹមនឹងនេះ មានកម្មករមួយចំនួនទទួលទានទឹកដាំពុះដែលដាក់ឬសឈើ ទទួលទានទឹកដែលយកមកពីរោងចក្រ ហើយខ្លះទៀតទទួលទានទឹកដែលបង្ហូរពីក្បាលរ៉ូប៊ីណេផ្ទាល់ផងដែរ។ កម្មករនៅតំបន់ទឹកថ្លានិយាយថា៖ *«ដាំទឹកសំបកឈើធម្មតា តែខ្ញុំគិតថាវាមិនមាន អនាម័យគ្រប់គ្រាន់ទេ តែគ្រាន់ថាវាអត់ធុំក្លិន ទឹកទុយោផឹកទៅធុំក្លិន»*។ កម្មករមួយរូបទៀតបន្ថែមថា៖ *«បើសម្រាប់ខ្ញុំវិញ មិនដែលយកពីរ៉ូប៊ីណេទេ ខ្ញុំយកពីរោងចក្រតែខ្ញុំមិនប្រាកដថា ទឹករោងចក្រហ្នឹងមានអនាម័យទេ យើងគ្មានលុយឯណាទៅទិញទឹកធុងមកផឹក យើងយកពីរោងចក្រហ្នឹងមួយថ្ងៃមួយដបៗ វាធូរលុយយើងដែរ»*។

## ១.២.៤ ការលាងសម្អាតដៃ

នៅតាមតំបន់បន្ទប់ជួលដ៏តូចចង្អៀត កម្មករពិបាកនៅក្នុងការបែងចែកឲ្យដាច់ពីគ្នាពីកន្លែងលាងដៃ កន្លែងបន្ទោរបង់ កន្លែងងូតទឹក និងកន្លែងចម្អិនអាហារ។ ជាក់ស្តែងកន្លែងលាងដៃរបស់កម្មករ គឺនៅជាប់នឹងបង្គន់ប្រើប្រាស់ប្រចាំថ្ងៃ (៥៤,៤ភាគរយ) នៅក្បែរពាងទឹក (១៤,៥ភាគរយ) និងក្បែរកន្លែងចម្អិនអាហារ (៧,២ភាគរយ) និងកន្លែងផ្សេងៗមិនកំណត់ជាក់លាក់ (១៨,៨ភាគរយ)។ កន្លែងលាងដៃខ្លះមានទឹក (៤៩,៥ភាគរយ) ខ្លះមានទឹកនិងសាប៊ូ។ កម្មការិនីកម្មករ ៦១,៣ភាគរយបានឲ្យដឹងថាកន្លែងលាងដៃ គឺមានទឹកនិងសាប៊ូដែលមានចំងាយតិចជាង៥ម៉ែត្រពីគ្នានេះក៏ដោយសារតែបន្ទប់របស់ពួកគាត់មានទំហំតូច។

ជាទំលាប់កម្មការិនីកម្មករលាងសំអាតដៃ នៅពេលដែលគាត់បន្ទោរបង់រួច (២៧,៦ភាគរយ) មុនពេលដែលបរិភោគអាហារ (២៦,៣ភាគរយ) និងក្រោយពីបរិភោគអាហាររួច (២១,២ភាគរយ) មុនពេលចម្អិនអាហារ (១៤,៧ភាគរយ) និងក្រោយពេលលាងគូថកូនក្មេង និងបញ្ចុកអាហារកូនក្មេង (៦,៩ភាគរយ) ។

**ការលាងសម្អាតដៃ**

| | ការឆ្លើយតប | |
|---|---|---|
| | ចំនួន | ភាគរយ |
| បន្ទាប់ចេញពីបង្គន់ | 60 | 27.6% |
| មុនពេលបរិភោគអាហារ | 75 | 26.3% |
| បន្ទាប់ពីបរិភោគអាហារ | 46 | 21.2% |
| មុនពេលចម្អិនអាហារ | 32 | 14.7% |
| បន្ទាប់ពីលាងគូថកូនក្មេង | 9 | 4.1% |
| មុនពេលបញ្ចុកអាហារក្មេង | 6 | 2.8% |
| ផ្សេងៗ | 7 | 3.2% |
| សរុប | 217 | 100% |

គិតជាភាគរយក្នុងចំណោម៧៥នាក់ (ជម្រើសច្រើន)

តាមការសង្កេតជាក់ស្តែង ដោយសារបង្គន់អនាម័យនៅឆ្ងាយពីបន្ទប់របស់គាត់ ដូច្នេះកម្មករខ្លះមិនបានលាងសម្អាតដៃនឹងសាប៊ូនោះទេ ជាពិសេសកម្មករដែលប្រើប្រាស់បង្គន់រួម។ នៅក្នុងបង្គន់រួមមួយចំនួនមិនមានទឹកប្រើប្រាស់គ្រប់គ្រាន់ និងសាប៊ូដើម្បីសម្អាតដៃឡើយ។ កម្មការិនីនៅតំបន់ចាក់អង្រែក្រោម៖ «*បន្ទប់ទឹកហ្នឹង ម្ចាស់ផ្ទះមិនដែលដាក់ទឹកទេ បើដាក់ទឹកវាសាច សាចពីដំបូលមក ហើយគាត់ក៏អត់វាយចោលដែរ គាត់ទុកនៅហ្នឹងដល់ពេលចូលទៅមូសហើរពីបន្ទប់ទឹក មានតែមូសហើយទឹកល្អក់ខ្មៅ ហើយវាមានក្លិនក្នុងទឹកហ្នឹងទៀត ពីព្រោះទឹកវាអត់ទៅណា ហើយពេលភ្លៀងខ្លាំងលូស្ទះ ទឹកហូរចូលក្នុងបន្ទប់ទឹកហ្នឹង*»។

### ១.២.៥ ការប្រើប្រាស់បង្គន់អនាម័យ គុណភាព និងសុវត្ថិភាព

តាមការស្ទង់មតិ កម្មករស្ទើរគ្រប់គ្នា (៩៥.៩ភាគរយ) ប្រើប្រាស់បង្គន់អនាម័យដែលបង្គន់ខ្លះត្រូវបានសង់ឡើងនៅក្នុងបន្ទប់នីមួយៗ (៥៧ភាគរយ) និងតំបន់ខ្លះទៀតប្រើប្រាស់បង្គន់រួម (៤៣ភាគរយ)។ ក្នុងប្លុកដែលប្រើប្រាស់បង្គន់រួមនីមួយៗមានបង្គន់ចាប់ពី៤បង្គន់ រហូតដល់៣០បង្គន់ ហើយមានអ្នកប្រើប្រាស់ពីម្នាក់រហូតដល់៦០០នាក់។ ជាមធ្យមបង្គន់មួយប្រើប្រាស់ដោយកម្មករចំនួន៣៤នាក់។ ការប្រើប្រាស់បង្គន់រួម និងបន្ទប់ទឹកសាធារណៈគឺជាបញ្ហា និងកង្វល់ដ៏ធំសម្រាប់កម្មការិនីកម្មករក្នុងការរស់នៅជាប្រចាំថ្ងៃ ដោយសារបន្ទប់ទឹករួមត្រូវបានប្រើប្រាស់នៅទីវាលល្ហល្ហេវ មិនមានការបិទបាំងអ្វីឡើយ ជាហេតុធ្វើឲ្យកម្មការិនីមានក្តីបារម្ភខ្លាំងក្នុងការសំអាតខ្លួនប្រាណ និងការធ្វើអនាម័យទៅលើផ្នែកបិទបាំងមួយចំនួននៃរាងកាយ។ មួយវិញទៀតបង្គន់ដែលប្រើប្រាស់រួមគ្នាចំនួន៤៨,៥ភាគរយ គឺមិនមានដំបូលប្រក់ពីលើដោយត្រឹមត្រូវ គ្មានអនាម័យ មានសត្វរុយតាមរោម និងមានក្លិនអាក្រក់ចេញពីបង្គន់ ពេលខ្លះមានលាមកអណ្តែតទៀតផង។ កម្មការិនីកម្មករតំបន់ចាក់អង្រែក្រោមបានឲ្យដឹងថា បង្គន់ប្រើប្រាស់រួមគ្នាស្ថិតនៅឆ្ងាយពីបន្ទប់ស្នាក់នៅ និងមិនមានភ្លើងបំភ្លឺគ្រប់គ្រាន់តាមផ្លូវឡើយ។ បង្គន់រួមមិនមានអ្នកជួយថែរក្សានិងអនាម័យ ព្រោះបង្គន់មិនមានសោត្រឹមត្រូវ ក្រៅពីអ្នកជួលបន្ទប់ក៏មានអ្នកខាងក្រៅ អាចប្រើប្រាស់បានដែរ។ កម្មការិនីនៅតំបន់ចាក់អង្រែក្រោម៖ «*បន្ទប់ហ្នឹងនិយាយទៅវាអត់ស្អាត ស័ង្កសីធ្លុះធ្លាយ ហើយអ្នកលក់ដូរនៅខាងមុខគេចូលបត់ដៃ*



*បត់ជើង ជួនកាលគេអត់ស្រួលខ្លួនចឹង (មានរដូវ) សំឡីអីគេអត់មានផ្លាស់ហើយដាក់ចង់អីទេ គេញាត់នៅក្នុងទ្វារបង្គន់ហ្នឹង... ជួនកាលមេឃភ្លៀងខ្លាំងហើយសាច ជឹងស្រាប់ហើយសំឡីយើងអត់ច្រកចង់ហើយពេលវាហៀរមកវាកខ្វក់ចឹង»។* ទន្ទឹមនឹងនេះ ម្ចាស់បន្ទប់ជួលក៏មិនមានវិធានការណាមួយក្នុងការរក្សាបង្គន់អនាម័យទាំងនោះ ពីព្រោះតែបង្គន់អនាម័យភាគច្រើនគ្មានធុងសំរាមគ្រប់គ្រាន់សម្រាប់ដាក់សំរាមឡើយ។




កម្មការិនី កម្មករចំនួន ៣៤៣,ភាគរយ បញ្ជាក់ថាបង្គន់មិនមានសុវត្ថិភាពក្នុងការប្រើប្រាស់ឡើយ ព្រោះគេអាចស្ដាប់ឮ ហើយ១៧,៩ភាគរយប្រើប្រាស់បង្គន់ដែលមិនអាចរក្សានូវភាពឯកជនរបស់ខ្លួន (ស្ដាប់ឮ និងមើលឃើញ)។ លើសពីនេះកម្មការិនីថ្លែងប្រាប់ថា៖ *«កន្លែងងូតទឹកមិនសូវសមរម្យទេព្រោះវានៅទីវាល ពេលខ្លះយើងស្រី ពេលទៅងូតទឹកមានប្រុសៗឈរមើលមកពួកយើង ... ហើយពេលខ្លះទៀតប្រព័ន្ធបង្ហូរទឹកក៏ស្ទះ»*។

## ១.២.៦ កាកសំណល់ និងប្រព័ន្ធលូ

### ១.២.៦.១ ការទុកសំរាម និងថ្លៃសេវា

កម្មការិនីកម្មករ ៣៣,៣ភាគរយ នៅក្នុងការស្រាវជ្រាវបានឆ្លើយតបថាពួកគាត់បានទុកសំរាមចោលនៅទីសាធារណៈ ខណៈដែល ២៩,៥ភាគរយ ទុកសំរាមនៅក្នុងធុងសំរាមរួម ហើយ ២៨,២ភាគរយទៀត ទុកក្នុងធុងសំរាមដាក់នៅខាងក្រៅបន្ទប់ជួលរបស់ខ្លួន និងមានកម្មការិនីកម្មករតែ ៨,៩ភាគរយ តែប៉ុណ្ណោះដែលទុកសំណល់ក្នុងធុងសំរាម ហើយដាក់ក្នុងបន្ទប់របស់ខ្លួន។ កម្មការិនីតំបន់ទឹកថ្លា៖ «*សំរាមគេចោលនៅមុខបន្ទប់ខ្ញុំហ្នឹង ពេលខ្យល់បក់មកវាស្អុយ*»។

ការចោលសំរាមនៅទីសាធារណៈបានធ្វើឲ្យប៉ះពាល់ខ្លាំងដល់បរិស្ថាន ប៉ុន្តែដោយសារតែគ្មានកន្លែងចោលសំរាមត្រឹមត្រូវទើបអ្នកជួលបន្ទប់បោះចោលសំរាមពាសវាលពាសកាល។ កម្មករនៅតំបន់ទឹកថ្លា៖ «*ម្ចាស់ផ្ទះអត់មានកន្លែងឲ្យចោលទេ តែគាត់យកលុយយើងថ្លៃសំរាម ១ដុល្លារ ក្នុងមួយខែ ហើយខ្ញុំដើរៗមើលឆ្វេងមើលស្ដាំបោះព្រុស ចោលយូរៗទៅគេដាក់ផ្លាកថា បើបោះចោលកន្លែងគេទៀត គេយក ១ដុល្លារ ដល់ចឹងខ្ញុំឈប់បោះហ្នឹង ខ្ញុំបោះចោលកន្លែងផ្សេងទៀត ខ្ញុំចងសំរាមឲ្យហើយស្រេច ដល់ម៉ោង ១០យប់ខ្ញុំយកទៅចោល*»។

## ការទុកដាក់សំរាម




គិតជាភាគរយក្នុងចំណោម៧៥នាក់

*១ដុល្លារ ដល់ចឹងខ្ញុំឈប់បោះហ្នឹង ខ្ញុំបោះចោលកន្លែងផ្សេងទៀត ខ្ញុំចងសំរាមឲ្យហើយស្រេច ដល់ម៉ោង ១០យប់ខ្ញុំយកទៅចោល*»។

កម្មការិនីកម្មករ ៧៤,៣ភាគរយ បានប្រាប់ឲ្យដឹងថា ពួកគាត់មិនបានចំណាយលុយលើថ្លៃបង់សំរាមនោះទេ។ ដោយឡែកកម្មការិនីកម្មករ ២៥,៧ភាគរយ បានឲ្យដឹងថាពួកគាត់ត្រូវចំណាយលុយលើការបង់ថ្លៃសំរាម១ដុល្លារក្នុងមួយខែ។ មូលហេតុដែលកម្មករត្រូវបង់ថ្លៃសេវាសំរាមព្រោះម្ចាស់បន្ទប់ជួលអះអាងថាគាត់ត្រូវចំណាយច្រើនទៅលើថ្លៃសេវាសំរាម។ ជាធម្មតាប្រជាជនដែលស្នាក់នៅផ្ទះល្វែង ហើយមិនមានប្រកបអាជីវកម្មណាមួយត្រូវបង់ថ្លៃសេវាសំរាម១ដុល្លារក្នុងមួយខែ បើធៀបជាមួយកម្មការិនីកម្មករដែលជួលបន្ទប់ស្នាក់នៅឃើញថាពួកគាត់បានចំណាយខ្ពស់លើថ្លៃសេវាសំរាម។

### ១.២.៦.២ ប្រព័ន្ធលូ

តាមរយៈការសម្ភាសន៍កម្មការិនីកម្មករ ៦០ភាគរយ បានឲ្យដឹងថានៅតំបន់រស់នៅរបស់ពួកគាត់តែងជួបប្រទះនឹងបញ្ហាស្ទះលូ។ កម្មករនៅតំបន់ចាក់អង្រែក្រោម៖ «*លូមានតែ២ នៅខាងជើងមួយនិងខាងត្បូងមួយ ហើយលូនឹងវាមានលក្ខណៈតូច ពេលភ្លៀងមកខ្លាំងគឺដឹងតែស្ទះលូ ហើយវាក៏ហូរចូលផ្ទះ*»។ បញ្ហាស្ទះលូនេះដោយសារតែប្រព័ន្ធលូមានចំនួនតិច ហើយអ្នករស់នៅក្នុងប្លុកជួលមានគ្នាច្រើនដូច្នេះកាកសំណល់ និងទឹកដែលប្រើប្រាស់រួចមានបរិមាណច្រើន ជាហេតុធ្វើឲ្យលូហូរមិនទាន់នាំឲ្យមានការកកស្ទះ ហើយធ្វើឲ្យបរិស្ថានរស់នៅមិនមានអនាម័យសម្រាប់កម្មការិនីកម្មករ។

# ផ្នែកទី២

## សន្តិសុខ និងសុវត្ថិភាព

## ២.១ ស្ថានភាពសន្តិសុខ

### ២.១.១ ករណីលួចនៅតាមបន្ទប់ជួល

តាមការស្រាវជ្រាវបានបង្ហាញថា នៅតាមតំបន់ដែលមានកម្មការិនីកម្មកររស់នៅយ៉ាងច្រើនកុះករនេះ ការរស់នៅរបស់ពួកគេនៅមិនទាន់មានសុវត្ថិភាពនៅឡើយទេ។ ក្នុងចំណោមកម្មករដែលបានសម្ភាសន៍មានកម្មករ ៥០,៧ភាគរយ បានឆ្លើយថាពួកគាត់បានជួបប្រទះនឹងករណីលួចនៅតាមបន្ទប់ជួលរបស់ខ្លួន។ ករណីលួចភាគច្រើនគឺបានកើតឡើងនៅពេលថ្ងៃ ៤៦ភាគរយ បើធៀបនឹងការលួច ដែលកើតឡើងនៅពេលល្ងាចដែលមានត្រឹមតែ ១១ភាគរយ ដោយសារតែនៅពេលថ្ងៃ ជាពេលដែលកម្មការិនីកម្មកររោងចក្រទៅធ្វើការងារ ហើយសោរចាក់ក៏មិនសូវមាំ។ កម្មករម្នាក់បានលើកឡើង៖ « *ខ្ញុំមិនបានឃើញចោរផ្ទាល់ទេ ប៉ុន្តែនៅពេលដែលខ្ញុំមកដល់ផ្ទះ ខ្ញុំរកធ្វើម្ហូបស្រាប់តែរបស់របរវាបាត់អស់ទៅហើយ គឺបន្ទប់ខ្ញុំចាក់សោរធម្មតាតែវាបាត់របស់អស់*«។ ម្យ៉ាងវិញទៀតនៅតាមប្លុកជួលមួយចំនួនគ្មានសន្តិសុខការពារសុវត្ថិភាពដល់អ្នកជួលនោះទេ ចំណែកឯនៅប្លុកមួយចំនួនដែលមានសន្តិសុខវិញ គឺពួកគេមើលថែតែម៉ូតូធ្វើដែលនៅខាងក្រោមអគារតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះម្ចាស់បន្ទប់ជួលមិនបានយកចិត្តទុកក្នុងការដើរមើលពេលកម្មការិនីកម្មករមិននៅបន្ទប់នោះទេ ហើយពួកគាត់ក៏មិនបានដឹងពីប្រវត្តិអ្នកជួលបន្ទប់ ឬថតចម្លងអត្តសញ្ញាណបណ្ណអ្នកជួល និងលិខិតអនុញ្ញាតការងារឡើយ ដែលជាហេតុធ្វើឲ្យជនខិលខូចមួយចំនួនមានឱកាសក្នុងការធ្វើសកម្មភាពលួច នៅពេលអ្នកជួលបន្ទប់ជិតខាងផ្សេងទៀតមិនបាននៅបន្ទប់របស់ខ្លួន។ ការលួចនៅតាមបន្ទប់ជួលបានកើតឡើងញឹកញាប់យ៉ាងហោចណាស់មួយខែមានមួយករណី។ កម្មការិនីនៅតំបន់ទឹកថ្លាបញ្ជាក់៖ « *ខ្ញុំគិតថាគ្មានសុវត្ថិភាពទេ ចុះបើឧស្សាហ៍បាត់នេះបាត់នោះរហូត សូម្បីខោអាវក៏បាត់ដែរ ហើយពេលខ្លះហាលខោអាវ បាត់ខោអាវ និយាយទៅបើយើងមានលុយទិញរបស់ល្អៗដាក់នៅបន្ទប់ ជួលត្រូវប្រយ័ត្នបន្តិច*«។



គិតជាភាគរយក្នុងចំណោម៧៥នាក់

## ភាពញឹកញឹប់នៃការឈ្លួចកើតឡើងតាមបន្ទប់ជួល




| | 1-7 ថ្ងៃ | 1 សប្តាហ៍ដល់ 1ខែ | ច្រើនជាង 1ខែ |
|---|---|---|---|
| គិតភាគរយ ក្នុងចំណោម៧៥នាក់ | 17.1 | 22.9 | 60 |

## ភាពញឹកញាប់ដែលករណីគាស់បន្ទប់កើតមានឡើង






គិតជាភាគរយក្នុងចំណោម៧៥នាក់

## ២.១.២ ករណីគាស់នៅតាមបន្ទប់ជួល

កម្មការិនីកម្មករ ១៧,៨ភាគរយបានឆ្លើយថា ពួកគាត់បានជួបករណីគាស់បន្ទប់ជួលរបស់ខ្លួន ហើយករណីនេះភាគច្រើនបានកើតឡើងនៅពេលថ្ងៃ (៧៥ភាគរយ)។ តាមការស្រាវជ្រាវករណីគាស់ ញឹកញាប់ដូចជាករណីលួច គឺក្នុងមួយខែមានម្តង «*លួចគាស់នៅពេលថ្ងៃពេលដែលចេញទៅធ្វើការ ពេលទៅចាក់សោរជាធម្មតាហើយ បិទហើយ ពេលមកវិញបាត់របស់អស់ គាស់យកទូរស័ព្ទ ពេលថ្ងៃក៏គាស់ដែរអូនទាំងយប់ទាំងថ្ងៃ*»។




គិតជាភាគរយក្នុងចំណោម៧៥នាក់

តាមស្ថានភាពជាក់ស្តែងម្ចាស់ផ្ទះ ឬម្ចាស់បន្ទប់ជួលមិនបានការពារសុវត្ថិភាពពេញលេញ សម្រាប់អ្នកជួលបន្ទប់ តាមរយៈការដាក់សន្តិសុខយាម ឬការត្រួតពិនិត្យមើលអ្នកចេញចូលអគារ អោយបានហ្មត់ចត់នោះឡើយ។ ទន្ទឹមនឹងនេះ ដែរបើក្រឡេកមើលពីស្ថានភាពបន្ទប់ជួលមួយចំនួនវិញ គឺសាងសង់ឡើងពីឈើដែលមានសភាពចាស់ទ្រុឌទ្រោម។ ទ្វារ និងបង្អួចវិញភាគច្រើនក៏

មិនសូវរឹងមាំដែលបង្កភាពងាយស្រួលសម្រាប់ចោរក្នុងការឆ្លុះឬគាស់។ អ្នកជួលបន្ទប់មិនអាចមានលទ្ធភាពចំណាយទិញសោរដែលរឹងមាំសម្រាប់ចាក់បន្ទប់របស់ខ្លួននោះទេ ពួកគាត់ភាគច្រើនទិញសោរដែលមានតម្លៃខ្ពស់បំផុតត្រឹម២ម៉ឺនរៀល។

## ២.១.៣ ការរាយការណ៍

រាល់ពេលកើតមានការលួច និងគាស់នៅតាមបន្ទប់ជួលនីមួយៗ កម្មការិនីកម្មករភាគច្រើនតែងរាយការណ៍ដល់ម្ចាស់បន្ទប់ជួល។ សម្រាប់ករណីលួចនៅតាមបន្ទប់ជួលកម្មការិនីកម្មករ ៦៤ ភាគរយបានរាយការណ៍ទៅម្ចាស់បន្ទប់ជួល ហើយកម្មការិនីកម្មករ ៣ភាគរយ បានរាយការណ៍ទៅអាជ្ញាធរភូមិ។ ដោយឡែកករណីគាស់បន្ទប់ជួលវិញ កម្មការិនីកម្មករ១០០ភាគរយបានរាយការណ៍ទៅម្ចាស់បន្ទប់ជួល។




មូលហេតុដែលកម្មការិនីកម្មកររាយការណ៍ទៅម្ចាស់បន្ទប់ជួល ព្រោះម្ចាស់បន្ទប់ជួលនៅជិត ឬនៅកន្លែងដែលពួកគាត់ស្នាក់នៅ។ ម្យ៉ាងវិញទៀតកម្មការិនី កម្មករភាគច្រើនមិនស្គាល់អាជ្ញាធរភូមិសង្កាត់នៅកន្លែងដែលពួកគាត់រស់នៅនោះទេ។ មិនតែប៉ុណ្ណោះកម្មការិនី កម្មករអះអាងថា ពួកគាត់គ្មានទំនុកចិត្តចំពោះអាជ្ញាធរក្នុងការដោះស្រាយ បើទោះជាគាត់រាយការណ៍។ សម្រាប់ការរាយការណ៍ទៅម្ចាស់បន្ទប់ជួលរាល់ពេលមានករណីលួច ឬគាស់បន្ទប់ក៏ហាក់ដូចជាគ្មានអ្វីប្រសើរឡើងនោះទេ ព្រោះបញ្ហាទាំងនេះនៅតែកើតមានឡើងជារឿយៗ។ លើសពីនេះទៀតម្ចាស់បន្ទប់ជួលមួយចំនួនមិនត្រឹមតែគ្មានដំណោះស្រាយឲ្យអ្នកជួលប៉ុណ្ណោះទេ ពួកគាត់ថែមទាំងស្តីបន្ទោសអ្នកបាត់របស់ទៀតផង។ កម្មករនៅតំបន់ពោធិ៍សែនជ័យ៖ ***«ពេលទៅប្រាប់ម្ចាស់ផ្ទះ ម្ចាស់ផ្ទះមិននិយាយស្រួលជាមួយយើងទេ មានតែស្តីឲ្យយើងថែមទៀត ថាមកពីយើងធ្វេសប្រហែស មិនចេះប្រយ័ត្នទុករបស់របរដោយខ្លួនឯង ស្តីឲ្យប្រាវៗតែម្តង»***។

### ២.១.៤ ភ្លើងបំភ្លឺច្រកចូលបន្ទប់ជួល







កម្មការិនីកម្មករ ៦៤នាក់ ស្មើនឹង ៨៥,៣ភាគរយ បានឆ្លើយតបថា នៅតាមច្រកចូលបន្ទប់ជួលរបស់ពួកគាត់មានបំពាក់ភ្លើងបំភ្លឺផ្លូវ ហើយម្ចាស់ផ្ទះជាអ្នកបំពាក់ដោយមិនបានគិតលុយពីអ្នកជួលនោះទេ។ កម្មការិនីកម្មករ ៦៤,៤ភាគរយអះអាងថា ភ្លើងបំភ្លឺផ្លូវទាំងនោះភ្លឺគ្រប់គ្រាន់សម្រាប់ពួកគាត់ធ្វើដំណើរនៅពេលយប់។ ទោះបីជាមានភ្លើងបំភ្លឺនៅតាមច្រកចូលបន្ទប់ជួលក៏ដោយ កម្មការិនីកម្មករនៅតែប្រឈមនឹងបញ្ហាអសុវត្ថិភាពតាមដងផ្លូវ ជាពិសេសកម្មការិនី កម្មករដែលមានបន្ទប់ជួលចូលឆ្ងាយជ្រៅ ហើយនៅតាមច្រកចូលបន្ទប់ជួលនីមួយៗភាគច្រើនមានសភាពតូចចង្អៀត និងស្ងប់ស្ងាត់ដែលជាឱកាសល្អសម្រាប់ជនខិលខូចមួយចំនួនបន្លំបៀតបៀនអ្នកជួលបន្ទប់ដទៃទៀត។

## ២.២ ស្ថានភាពសុវត្ថិភាព

### ២.២.១ ក្មេងទំនើង

បញ្ហាក្មេងទំនើងបានកើតឡើងស្ទើរតែគ្រប់ប្លុកបន្ទប់ជួលរបស់កម្មការិនីកម្មករ។ កម្មការិនី កម្មករ ៥៧,៧ភាគរយបានឆ្លើយតបថា នៅក្នុងប្លុកផ្ទះជួលរបស់ពួកគាត់មានក្មេងទំនើង។ ប៉ុន្តែទាំងម្ចាស់បន្ទប់ជួល និងអាជ្ញាធរមូលដ្ឋាននៅតែគ្មានចំណាត់ការណាមួយពីបញ្ហានេះទេ។ ម្ចាស់បន្ទប់ជួលមិនបានសហការជាមួយអាជ្ញាធរដើម្បីមានវិធានការណាមួយក្នុងការ បង្ក្រាបពួកគេ នៅពេលដែលពួកគេមិនគោរពតាមបទបញ្ជាផ្ទៃក្នុង ឬបង្កការរំខានណាមួយដល់អ្នកជិតខាង។ ក្មេងទំនើង ៨៩ភាគរយបានផឹកស្រវឹងឡូឡាវាយតប់គ្នា និងបង្កការរំខាននានាដល់អ្នកជួលបន្ទប់ផ្សេងដែលនៅក្បែរ។ កម្មការិនី

នៅតំបន់ពោធិ៍សែនជ័យបានលើកឡើងថា៖ «*ដូចយប់មិញខ្ញុំដើរទៅទិញបង្អែមរៀងយប់បន្តិចដើរទៅប៉ះស្វាវាងក្មេងៗដែរ ដល់ពេលអញ្ចឹងទៅវាងខ្លាចដែរ។ និយាយរួមទៅប្រសិនជាអាចអត់ចង់ចុះទេនៅពេលយប់។ ពេលខ្លះមានសំលេងរំខានមកពីធ្វើការអស់កំលាំងពិបាកសំរាក ព្រោះឮសំលេងរំខាន*»។ កម្មការិនីតំបន់ចាក់អង្រែក្រោម៖ «*អ្នកខ្លះផឹកដល់ម៉ោង១០ ម៉ោង១១យប់ឈ្លោះគ្នា ហើយក្អួតពេញហ្នឹង*»។ បន្ថែមពីលើនេះទៀត អ្នកជួលបន្ទប់តែងតែនៅចម្រុះគ្នា ហើយអ្នកខ្លះធ្វើការផ្លាស់ប្តូរទីតាំងញឹកញាប់ពីតំបន់មួយទៅតំបន់មួយទៀតនៅពេលមានបញ្ហា ហេតុនេះក្មេងទំនើងមានឱកាសក្នុងការប្រព្រឹត្តអំពើនានាដោយមិនគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់បន្ទប់ជួល ដោយសារពួកគេអាចផ្លាស់ប្តូរកន្លែងស្នាក់នៅបានស្រួល។

## បញ្ហាក្មេងទំនើងដែលកើតឡើងនៅកន្លែងរស់នៅ

| | ការឆ្លើយតប | |
|---|---|---|
| | ចំនួន | ភាគរយ |
| ការវាយតប់គ្នា | 19 | 23.2% |
| ផឹកស្រវឹងឡូឡា | 33 | 40.2% |
| បង្ករការរំខាន | 21 | 25.6% |
| ផ្សេងៗ | 9 | 11% |
| សរុប | 82 | 100% |

គិតជាភាគរយក្នុងចំណោម៧៥នាក់ (ជម្រើសច្រើន)

### ២.២.២ ការប្រើប្រាស់ ឬជួញដូរគ្រឿងញៀន

កម្មករ ៨២,៩ភាគរយ បានឲ្យដឹងថា ប្លុកជួលបន្ទប់របស់ពួកគាត់គ្មានការប្រើប្រាស់ ឬជួញដូរគ្រឿងញៀននោះទេ។ ដោយឡែកកម្មករ ១៧,១ភាគរយ អះអាងថា នៅក្នុងប្លុកបន្ទប់ជួលរបស់ពួកគាត់មានការប្រើប្រាស់ ឬជួញដូរគ្រឿងញៀន។ កម្មករម្នាក់បានឲ្យដឹងថា៖ « *ដក់ពេលយប់ ព្រោះតែខ្ញុំដេកពេលយប់នោះ ម៉ោង១២យប់ ស្រាប់តែលឺមាត់គេមកហៅអ្នកនេះហៅអ្នកនោះ ហើយយើងមិនដឹងទេថា ជាអ្នកណាតែគ្នាគេគឺដឹងហើយថា មកហៅធ្វើអ្វីនោះ ហើយលឺសួរថាឯងយកដែរ ឬអត់?*»

ការប្រើប្រាស់ ឬជួញដូរគ្រឿងញៀនគឺបញ្ហាមួយដែលត្រូវបានជនខិលខូចប្រព្រឹត្តឡើង ដោយស្ងាត់កំបាំង ជាហេតុធ្វើឲ្យអ្នកជួលបន្ទប់មួយចំនួនមិនបានដឹងពីបញ្ហានេះទេ។ ដោយឡែកកម្មការិនីកម្មករមួយចំនួនមានការខ្លាចរអាក្នុងការនិយាយពាក់ព័ន្ធនឹងបញ្ហានេះ។

### ២.២.៣ ការលេងល្បែងស៊ីសង

កម្មការិនី កម្មករ ៧៨,៩ភាគរយ បានឆ្លើយតបថា នៅប្លុកជួលបន្ទប់របស់ពួកគាត់មានការលេងល្បែងស៊ីសង។ ល្បែងស៊ីសងដែលគេនិយមលេងគឺការលេងបៀរចំនួន ៤៥,៦ភាគរយ និងការចាក់ឆ្នោត ចំនួន៤៣,៧ភាគរយ។ កម្មករនៅតំបន់ពោធិ៍សែនជ័យនិយាយថា៖ *«លេងល្បែងស៊ីសងហ្នឹងមានរាល់តែយប់ រាល់តែថ្ងៃតែម្តង មានលេងបៀរ ចាក់ឆ្នោតអីហ្នឹង»* ។

**ប្រភេទល្បែងស៊ីសងដែលកើតឡើងនៅប្លុកបន្ទប់ជួល**

| | ការឆ្លើយតប | |
|---|---|---|
| ប្រភេទ | ចំនួន | ភាគរយ |
| ចាក់ឆ្នោត | 45 | 43.7% |
| លេងបៀ | 47 | 45.6% |
| ល្បែងជល់មាន់ | 3 | 2.9% |
| លេងអាប៉ោង | 7 | 6.8% |
| ផ្សេងៗ | 1 | 1% |
| សរុប | 103 | 100% |

គិតជាភាគរយក្នុងចំណោម៧៩នាក់ (ជម្រើសច្រើន)

តាមរយៈការសិក្សាបង្ហាញឲ្យឃើញថា ល្បែងស៊ីសងបានក្លាយជាល្បែងដ៏ពេញនិយមពីព្រោះតែមិនមានការទប់ស្កាត់ពីម្ចាស់បន្ទប់ជួល ក៏ដូចជាអាជ្ញាធរដែលធ្វើការលេងល្បែងស៊ី សងនេះក្លាយជារឿងដែលប្រព្រឹត្តដោយបើកចំហ។

### ២.២.៤ ការបៀតបៀនកេរ្តិ៍ខ្មាស

កម្មការិនីកម្មករ ៣៨,៩ភាគរយ អះអាងថា ពួកគាត់ធ្លាប់ត្រូវបានគេបៀតបៀនកេរ្តិ៍ខ្មាស។ សកម្មភាពបៀតបៀនកេរ្តិ៍ខ្មាសនេះភាគច្រើន (៨១,៨ភាគរយ) គឺបៀតបៀនតាមរយៈពាក្យសំដី។ កម្មការិនីអះអាងថា បញ្ហានេះកើតឡើងរៀងរាល់សប្តាហ៍ (៣៧ភាគរយ) បានកើតឡើងនៅពេលថ្ងៃ ៣១,៣ភាគរយ ពេលល្ងាច ៣៤,៤ភាគរយ ហើយច្រើនកើតមានឡើងនៅតាមផ្លូវធ្វើដំណើរទៅមកធ្វើការ។ កម្មករនៅតំបន់ពោធិ៍សែនជ័យ៖ *«ខ្ញុំជួបម្តងដែរនៅពេលចេញពីថែមម៉ោងការងារពេលយប់ ពេលដើរតាមផ្លូវជួបពួកវាមួយក្រុមប្រហែលជា៣ទៅ ៤នាក់ ដើរមករកេចាប់ តែពេលនោះខ្ញុំរត់ទាន់»* ។

កម្មការិនីភាគច្រើនមិនបានយល់ថា អ្វីទៅជាការបៀតបៀនកេរ្តិ៍ខ្មាសនោះទេ ពួកគាត់យល់ថា គ្រាន់តែគេហៅអូនបង ឬការហួចលេងគឺជារឿងធម្មតារបស់មនុស្សប្រុស ហើយប្រសិនបើគាត់ជជែកតវ៉ានោះនាំឲ្យមានបញ្ហាកើតឡើង។ កម្មការិនីនៅតំបន់ពោធិ៍សែនជ័យ៖ *«ថ្ងៃមុនខ្ញុំដើរទៅទិញអីញ៉ាំរៀងយប់ដែរ ប្រហែលជាម៉ោង៨ ទៅម៉ោង៨កន្លះ អីនឹង ស្រាប់តែមានប្រុសបក់ដៃហៅថា អេអូនមកធ្វើអីហ្នឹង ប៉ុន្តែខ្ញុំទ្រាំ ខ្ញុំគិតថាយើងជាស្ត្រី បើយើងនិយាយច្រើនអីទៅ វាអាចមានបញ្ហា តែបើយើងធ្វើធម្មតាៗទៅវាមិនអីទេ»។* ម្យ៉ាងវិញទៀតស្ត្រីមានភាពអៀនខ្មាសច្រើនពិបាកក្នុងការរាយការណ៍ និងសុំការអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន ជាហេតុបណ្តាលឲ្យបញ្ហានេះចេះតែរីករាលដាលឡើងៗ។

**ការបៀតបៀនកេរ្តិ៍ខ្មាស់កើតឡើងតាមរយៈ**




គិតជាភាគរយក្នុងចំណោម៧៥នាក់

**កន្លែងដែលកើតមានការបៀតបៀនកេរ្តិ៍ខ្មាស់**




គិតជាភាគរយក្នុងចំណោម៧៥នាក់

### ២.២.៥ ការអន្តរាគមន៍ពីអាជ្ញាធរក្នុងតំបន់

កម្មករ ៩៦ភាគរយបានលើកឡើងថា នៅពេលពួកគាត់ជួបប្រទះនឹងការបៀតបៀនកេរ្តិ៍ខ្មាស ពួកគាត់មិនធ្លាប់ទទួលបានការអន្តរាគមន៍ណាមួយពីអាជ្ញាធរក្នុងតំបន់នោះទេ។ មូលហេតុដែលគ្មានការអន្តរាគមន៍គឺមកពីកម្មករមិនបានរាយការណ៍ទៅអាជ្ញាធរ ព្រោះកម្មករមិនបានស្គាល់អាជ្ញាធរមូលដ្ឋាន ឬមិនមានទំនុកចិត្តចំពោះអាជ្ញាធរមូលដ្ឋាន។ ទន្ទឹមនឹងនេះដែរ បើយករឿងកេរ្តិ៍ខ្មាសរបស់ស្ត្រីទៅប្រាប់អាជ្ញាធរដែលសុទ្ធតែជាមនុស្សប្រុសៗអាចជាមូលហេតុមួយដែលធ្វើឲ្យពួកគាត់មិនហ៊ានក្នុងការរាយការណ៍ផងដែរ។

### ២.២.៦ ប្រជាការពារភូមិ និងប៉ុស្តិ៍យាម

តាមរយៈការសម្ភាសកម្មការិនីកម្មករ ៩៤,៥ភាគរយបានឆ្លើយតបថា ពួកគាត់មិនស្គាល់ប្រជាការពារភូមិនោះទេ ហើយ៩១,៥ភាគរយឆ្លើយថា ពួកគាត់មិនដែលឃើញមានប៉ុស្តិ៍ប៉ូលិសនៅតំបន់គាត់រស់នៅទេ។ ការមិនស្គាល់ពីប្រជាការពារភូមិ និងប៉ូលិសបានបង្ហាញទាំងកម្មការិនីកម្មករ ប្រជាការពារភូមិ និងប៉ូលិសមិនបានសហការគ្នានោះទេ។ ការនេះជាចំណុចចន្លោះប្រហោងមួយដែលតម្រូវ

ឲ្យអាជ្ញាធរប៉ូលិស និងប្រជាការពារភូមិគប្បីធ្វើយ៉ាងណាឧស្សាហ៍ចុះជួបប្រជាពលរដ្ឋ និងកម្មការិនីកម្មករដែលរស់នៅតំបន់ស្នាក់ការរបស់ខ្លួន ដោយពន្យល់ពីទីតាំងនិងផ្តល់ការទំនាក់ទំនងរបស់ខ្លួនឲ្យបានច្បាស់លាស់ ដើម្បីឲ្យប្រជាជនបានរាយការណ៍ទាន់ពេលនៅពេលមានហេតុការណ៍ណាមួយកើតឡើង។

កម្មការិនីកម្មកររោងចក្រ បាននិងកំពុងប្រឈមនឹងបញ្ហាសុវត្ថិភាពជាខ្លាំងក្នុងការរស់នៅរបស់ពួកគាត់ ដែលផ្ទុយទៅនឹងគោលនយោបាយភូមិឃុំសុវត្ថិភាពចែងអំពីលក្ខណសម្បត្តិទាំងប្រាំយ៉ាងគឺ គ្មានសកម្មភាព លួច ឆក់ ប្លន់គ្រប់ប្រភេទ គ្មានការផលិតចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្មានអំពើអាណាចារ្យ គ្មានការជួញដូរស្ត្រី កុមារ និងអំពើហិង្សាក្នុងគ្រួសារ គ្មានក្មេងទំនើង គ្មានការលេងល្បែងស៊ីសងខុសច្បាប់។

# ផ្នែកទី៣

## ស្ថានភាពបន្ទប់រស់នៅ

### ៣.១ ស្តង់ដារបន្ទប់ជួល និងបរិក្ខា

### ៣.១.១ ស្ថានភាពជុំវិញបន្ទប់ជួល

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងតំបន់ចំនួនបី ដែលមានតំបន់ពោធិ៍សែនជ័យ ទឹកថ្លា និង ចាក់អង្រែក្រោម។ ក្នុងមួយតំបន់មានបីប្លុក ក្នុងមួយប្លុកមានបន្ទប់ចាប់ពី៥០ឡើង។ តាមការស្រាវជ្រាវរកឃើញថាចំនួនអ្នករស់នៅក្នុងបន្ទប់នីមួយៗចន្លោះ១នាក់ទៅ៥នាក់។ បន្ទប់ជួលដែលកម្មកររស់នៅ គឺមានចាប់ពីជាន់ផ្ទាល់ដីរហូតដល់ជាន់ទី៥ ក្នុងនោះជាន់ដែលកម្មកររស់នៅច្រើនជាងគេ គឺនៅជាន់ផ្ទាល់ដីដែលមានរហូតដល់ ៥០,៣ភាគរយ បើធៀបនឹងចំនួនកម្មករដែលរស់នៅជាន់ទី២ មាន ២០ ភាគរយ ចំណែកឯកម្មករដែលរស់នៅមានចំនួនភាគរយតិចជាងគឺនៅជាន់ទី៥ត្រឹមតែ ១,៣ភាគរយ។

របងអគារ/ប្លុកបន្ទប់ជួល




គិតជាភាគរយក្នុងចំណោម៧៥នាក់

នៅតាមតំបន់ដែលមានបន្ទប់ជួល ម្ចាស់ផ្ទះបានធ្វើអគារដែលមានរបងហ៊ុមព័ទ្ធដោយស៊ីម៉ង់ត៍ ដែក និងឈើ ហើយកន្លែងខ្លះមិនមានរបងហ៊ុមព័ទ្ធនោះទេ។

ចំនួនជាន់នៃបន្ទប់ជួលកម្មករ




គិតជាភាគរយក្នុងចំណោម៧៥នាក់




## ៣.១.២ ទំហំបន្ទប់ជួល

ក្នុងចំណោមកម្មការិនីកម្មករដែលបានសម្ភាសន៍ ៧៥នាក់ មានចំនួន២៥,៣ភាគរយ ដែលជួលបន្ទប់ទំហំ៣ម៉ែត្រគុណ៤ម៉ែត្រ ១៩,៩ភាគរយ បានជួលបន្ទប់ទំហំ២,៥ម៉ែត្រគុណ៣ម៉ែត្រ និង ១៧,៣ភាគរយ ជួលបន្ទប់ទំហំ២ម៉ែត្រគុណ៣ម៉ែត្រ ហើយទំហំបន្ទប់ដែលកម្មកររស់នៅតិចជាងគេមានទំហំចន្លោះពី ២ម៉ែត្រ គុណ ១ម៉ែត្រកន្លះ រហូតដល់ ៨ម៉ែត្រ។ បន្ទប់ជួលទាំងនោះភាគច្រើនមានស្ថានភាពពិបាកក្នុងការរស់នៅ ដោយមានជញ្ជាំងធ្វើពីក្តារបន្ទះកុងផ្លាកេ ជ្រាបទឹក លិចទឹក និងក្តៅហប់។ កម្មការិនីនៅតំបន់ចាក់អង្រែក្រោម៖ «***បើគំនិតខ្ញុំវាខុសទំនងត្រង់ជញ្ជាំង ពីព្រោះជញ្ជាំងជាប់គ្នានឹងដាក់កុងផ្លាកេ ហើយខាងលើចំហពាក់កណ្តាល ប្រសិនជាគាត់ធ្វើថ្មវិញ ខ្ញុំគិតថាពួកខ្ញុំមានសុវត្ថិភាព***»។ កម្មករម្នាក់ទៀតបានលើកឡើង៖ «***បើផ្ទះជួលខ្ញុំវិញបន្ទប់ខាងលើអត់អីទេ តែបើខាងក្រោម បើមេឃភ្លៀងខ្លាំងមិនដឹងថាវាជ្រាបទឹកមកពីខាងណាវិញ វាជ្រាបពីក្រោម លិចក្រោមគ្រែហ្នឹងតែម្តង***»។ កម្មការិនីនិងកម្មកររោងចក្របានចំណាកស្រុកមករកការងារធ្វើនៅរាជធានីភ្នំពេញ ពួកគេត្រូវជួលបន្ទប់សម្រាប់ស្នាក់នៅដែលនៅក្បែររោងចក្រ ហើយស្ថានភាពដែលបានរៀបរាប់ខាងលើបានកំពុងធ្វើឲ្យគុណភាពនៃជីវិតរស់នៅរបស់ពួកគេមិនមានភាពប្រសើរឡើយ។ បើពិនិត្យមើលលើគោលនយោបាយជាតិស្តីពីលំនៅឋានត្រង់ជម្រើសទី៩ *ការធានាលំនៅឋានសម្រាប់កម្មករនិយោជិត* បានចែងថា «*គួរជំរុញឲ្យនិយោជកចូលរួមចំណែកក្នុងការរៀបចំលំនៅឋាន ឬកន្លែងស្នាក់នៅសមរម្យមានប្រព័ន្ធទឹកស្អាត អគ្គិសនី មានអនាម័យ និងបរិស្ថានល្អសម្រាប់កម្មករនិយោជិត ដែលប្រសិទ្ធភាពនៃការអនុវត្តអាចធ្វើទៅបានតាមរយៈច្បាប់ស្តីការងារ*»។ [2] ការអនុវត្តដាក់ស្តែងពីលំនៅឋាន គឺនៅមិនទាន់បានពេញលេញនៅ

---

[2] គោលនយោបាយជាតិស្តីពីលំនៅឋាន, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ២០១៤, ទំ.៤ ជម្រើសដើម្បីទទួលបានលំនៅឋាន, ជម្រើសទី៩

ឡើយទេ  តាមតំបន់ខ្លះមាននិយោជកមួយចំនួនបានរៀបចំកន្លែងស្នាក់នៅជូនដល់កម្មករនិយោជិត ជាពិសេសនៅតាមតំបន់សេដ្ឋកិច្ចពិសេសនៅក្រុងភ្នំពេញ  តែក៏មាននិយោជកភាគច្រើនទៀតបានផ្តល់ប្រាក់៧ដុល្លារ  ជំនួសការផ្តល់កន្លែងស្នាក់នៅដល់កម្មករនិយោជិត។  ប្រាក់ឧបត្ថម្ភស្នាក់នៅមានចំនួនតិចតួច  បើធៀបនឹងតម្លៃបន្ទប់ជួលនីមួយៗដែលបណ្តាលឲ្យកម្មការិនីកម្មករនិយោជិតសម្រេចជួលបន្ទប់ដែលមានទំហំតូចចង្អៀតមិនមានស្តង់ដាររស់នៅរួមគ្នាជាមួយកម្មការិនីកម្មករផ្សេងទៀត។

### ៣.១.៣ តម្លៃបន្ទប់ជួល

បន្ទប់ដែលកម្មការិនីកម្មករជួលមានតម្លៃចន្លោះពី ២០ដុល្លារ ទៅដល់ ៤៥ដុល្លារ។ កម្មការិនីកម្មករ ៨៨,៧ភាគរយ បានឲ្យដឹងថាបន្ទប់ជួលរបស់ពួកគាត់មិនមានការឡើងថ្លៃនោះទេ។ ដោយសារ




អំឡុងពេលធ្វើបទសម្ភាសន៍ប្រព្រឹត្តទៅនៅពាក់កណ្តាលឆ្នាំ    ការសម្ភាសន៍មិនអាចកំណត់ពីការរងថ្លៃបន្ទប់ជួលបានទេ។  តាមរយៈក្រុមពិភាក្សាបានបញ្ជាក់ពីមូលហេតុដែលមិនមានការឡើងថ្លៃបន្ទប់  គឺដោយសារបន្ទប់ទាំងនេះភាគច្រើនឡើងថ្លៃនៅពេលដើមឆ្នាំ  ជាពិសេសពេលប្រាក់ឈ្នួលកម្មករឡើង។ កម្មករនៅតំបន់ពោធិ៍សែនជ័យ៖ *«បន្ទប់តូចហើយថ្លៃទៀត ប្រាក់ខែតិច  បន្ទប់ជួលនេះចេះតែឡើងថ្លៃ បន្ទប់តំលៃ ៥០$ ទៅ ៦០$ ឲ្យយើងរស់នៅយ៉ាងម៉េចបើប្រាក់ខែតិចតួចហ្នឹង»។*  កម្មករម្នាក់ទៀតនៅ

តំបន់ដដែលបានលើកឡើងថា៖ «*បើរកមូលហេតុ (ឡើងថ្លៃបន្ទប់) មិនបាច់រកទេ មានតែប៉ុណ្ណឹង (ប្រាក់ឈ្នួលឡើងថ្លៃ) ដឹងថាដោយសារតែ រឿងប៉ុណ្ណឹង*»។

ដោយឡែកកម្មការិនី កម្មករ ១១,៣ភាគរយ បានឲ្យដឹងថាបន្ទប់ជួលរបស់ពួកគេមានការឡើងថ្លៃក្នុងអំឡុងពេលសម្ភាសន៍។ កម្មករនៅតំបន់ចាក់អង្រែក្រោម៖ «*បន្ទប់ជួលខ្ញុំតូច តែឡើងថ្លៃ ២០ដុល្លារ ហើយជញ្ជាំងធ្វើពីកុងផ្លាកេ ដោយមានប្រហោងធ្លុះដែលអាចមើលឃើញពីបន្ទប់មួយទៅបន្ទប់មួយបាន*»។ កម្មករម្នាក់ទៀតបញ្ជាក់ថា៖ «*តម្លៃម្នាក់ ២០ដុល្លារ បើពីរនាក់ ២២ដុល្លារ ហើយបន្ទប់ខ្លះទៀតនៅពេលនៅម្នាក់ឯង ២២ដុល្លារ នៅពេលថែមម្នាក់ទៀតយក ២៣ដុល្លារ ២៤ដុល្លារតាមហ្នឹង ហើយបើថ្លៃទឹកយកម្នាក់ ១ដុល្លារ*»។

នៅក្នុងច្បាប់ភតិសន្យាពិសេសដែលបានអនុម័តឆ្នាំ ២០១៥ ត្រង់ជំពូក២ មាត្រា ៦ បានចែងថា ភតិសន្យាពិសេសមានអត្ថិភាពក្នុងអំឡុងពេលមិនតិចជាង ២ឆ្នាំ (ពីរ) ឆ្នាំ។ ភតិសន្យាពិសេសដែលមិនកំណត់អំឡុងពេល ឬកំណត់អំឡុងពេលតិចជាង២ (ពីរ)ឆ្នាំ ត្រូវចាត់ទុកថាមានអត្ថិភាពអំឡុងពេល២ (ពីរ) ឆ្នាំ។ ជាមួយគ្នានេះដែរ មាត្រា៨ បានចែងថា ក្នុងអំឡុងពេលដែលភតិសន្យាពិសេសមានអនុភាពអនុវត្តភតិបតី (ម្ចាស់បន្ទប់ជួល) មិនអាចតម្លើងថ្លៃឈ្នួលបានឡើយ។ បើតាមស្ថានភាពជាក់ស្តែង ម្ចាស់ផ្ទះជួលមិនបានអនុវត្តតាមច្បាប់នេះទេ ម្ចាស់ផ្ទះខ្លះបានដំឡើងថ្លៃបន្ទប់ជួលនៅពេលបានដឹងថា ប្រាក់ឈ្នួលកម្មករនឹងត្រូវដំឡើងនៅដើមឆ្នាំបន្ទាប់។ ពួកគេបានផ្តល់ដំណឹងដំឡើងថ្លៃមុនប្រហែលជា២ទៅ៣ខែមុនប្រាក់ឈ្នួលឡើង។ ច្បាប់ភតិសន្យាពិសេសនេះអនុវត្តឲ្យដំឡើងថ្លៃបន្ទប់បន្ទាប់ពី២ឆ្នាំនៃកិច្ចសន្យា គឺម្ចាស់ផ្ទះជួលមិនអាចឡើងថ្លៃបន្ទប់ជួលតាមចិត្តនោះបានទេនៅអំឡុងពេល ២ឆ្នាំ ហើយរាល់ការឡើងថ្លៃគួរមានជជែកចរចាគ្នាជាមួយអ្នកជួលបន្ទប់។

## ៣.១.៤ បទបញ្ជាផ្ទៃក្នុងបន្ទប់ជួល

កម្មការិនី កម្មករ ៥៩,៥ភាគរយ បានឆ្លើយថាម្ចាស់ផ្ទះជួលបានដាក់បទបញ្ជាផ្ទៃក្នុង[3] សម្រាប់អ្នកជួលបន្ទប់របស់គាត់ ហើយកម្មការិនីកម្មករ ៩៣,២ភាគរយ អះអាងថាបទបញ្ជាផ្ទៃក្នុងទាំងនោះមានលក្ខណៈសមស្របអាចទទួលយកបាន។ ដោយឡែកកម្មការិនី កម្មករ ៤០,៥ភាគរយ បានឆ្លើយថាបន្ទប់ជួលរបស់ពួកគាត់គ្មានបទបញ្ជាផ្ទៃក្នុងនោះទេ។ បើទោះជាបន្ទប់ជួលភាគច្រើនមានបទបញ្ជាផ្ទៃក្នុង ប៉ុន្តែការអនុវត្តនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយទេ។ ទន្ទឹមនឹងនេះកម្មករខ្លះបានត្អូញត្អែរ

---

[3] បទបញ្ជាផ្ទៃក្នុងរបស់បន្ទប់ជួលនីមួយៗខុសគ្នាពីប្លុកមួយទៅប្លុកមួយ ប៉ុន្តែជារួម បទបញ្ជាផ្ទៃក្នុងទាំងនោះ ភាគច្រើនចែងអំពីការហាមមិនឲ្យលេងល្បែងស៊ីសង ការផឹកស៊ីឡូឡា និងបិទទ្វាររបងម៉ោង ៩ ឬម៉ោង ១០យប់

ពីការរំខាននានានៅពេលយប់អាធ្រាត្រ ដូចជាកម្មករនៅតំបន់ទឹកថ្លាបានលើកឡើងថា៖ *«ខ្ញុំវាពិបាក យប់ឡើងជួនណាគេលេងល្បែងនៅមុខបន្ទប់លេងទល់ម៉ោងមួយ ម៉ោងពីរ ជួនភ្លឺក៏មាន។ ខ្ញុំដេកអត់បានទេ។ ពេលខ្ញុំទៅប្រាប់គេ គេឈប់លេងបានមួយថ្ងៃ គេទៅគោះទ្វារខ្ញុំកណ្ដាលអាធ្រាត្រ។ ពេលហ្នឹងខ្ញុំខ្លាចដែរ»*។




## ៣.១.៥ កិច្ចសន្យាបន្ទប់ជួល

កម្មការិនី កម្មករ ៤,១ភាគរយ មានកិច្ចសន្យាបន្ទប់ជួល ចំណែកអ្នកគ្មានកិច្ចសន្យាបន្ទប់ជួលមាន ៩៥,៩ភាគរយ។ ក្នុងចំណោមកម្មការិនី កម្មករដែលគ្មានកិច្ចសន្យា ៦១,២ភាគរយ មិនចង់បានកិច្ចសន្យានោះទេ ព្រោះគាត់យល់ថាកិច្ចសន្យាគឺជាការចងពួកគាត់មិនឲ្យមានសេរីភាពក្នុងការផ្លាស់ប្ដូរបន្ទប់ជួល។ ម្យ៉ាងវិញទៀតដោយសារការងារនៅតាមរោងចក្រភាគច្រើនប្រើប្រាស់កិច្ចសន្យាខ្លី ពេលកិច្ចសន្យាការងារត្រូវបានបញ្ចប់ពួកគាត់នឹងត្រូវទៅរកការងារធ្វើនៅកន្លែងផ្សេងទៀត ហេតុដូច្នេះពួកគាត់យល់ថា បើមានកិច្ចសន្យាបន្ទប់ជួលគឺពួកគាត់មិនអាចរើចេញមុនកិច្ចសន្យាត្រូវបានបញ្ចប់នោះទេ ហើយបើគ្មានកិច្ចសន្យាពួកគាត់ងាយស្រួលក្នុងផ្លាស់ប្ដូរបន្ទប់ជួលតាមតម្រូវការរបស់ពួកគាត់ជាង។

មានមូលហេតុផ្សេងទៀតដែលគាត់មិនចង់បានកិច្ចសន្យា ព្រោះពួកគាត់មិនយល់ច្បាស់ថាអ្វីទៅជាកិច្ចសន្យានោះទេ។ កម្មករតំបន់ចាក់អង្រែក្រោម៖ «*គ្មានកិច្ចសន្យាទេព្រោះមិនដឹងថាកិច្ចសន្យាអីផង*»។ កម្មករនៅតំបន់ទឹកថ្លា៖ *«មានកិច្ចសន្យាទាល់តែយើងជួលផ្ទះល្វែង ... បន្ទប់លក្ខណៈតូចៗអត់មានកិច្ចសន្យា។ តែបើគេកំណត់ថាប៉ុន្មានឆ្នាំ តម្លៃប៉ុន្មានរយ ឬថា១ឆ្នាំ ៧០០ដុល្លារ អញ្ចឹងទើបមានកិច្ចសន្យា»*។ ការណ៍នេះអាចបញ្ជាក់បានថា ទាល់តែតម្លៃបន្ទប់ ឬផ្ទះមានតម្លៃថ្លៃទើបកិច្ចសន្យាជួលត្រូវបានប្រើប្រាស់។

នៅពេលកម្មការិនីកម្មករជួលបន្ទប់ដោយគ្មានកិច្ចសន្យាជួលបានធ្វើឲ្យពួកគាត់ប្រឈម នឹងស្ថានភាពលំបាកដូចជាទីមួយ ការទារថ្លៃសេវាកម្មភ្លើង «*លុយបង់ថ្លៃភ្លើងគេមិនឲ្យយើងទៅបង់ទេ គឺគេឲ្យបង់តាមរយៈម្ចាស់ផ្ទះ។ បើអ្នកណាមិនបង់តាមម្ចាស់ផ្ទះ គេគំរាមឲ្យរើបន្ទប់ចេញពេលបង់លុយ ថ្លៃភ្លើងគឺម្ចាស់ផ្ទះយកលុយថ្លៃសេវាបន្ថែមទៀត*»។ ទីពីរ ការបញ្ឈប់ជួលបន្ទប់ពីផ្ទះម្ចាស់ជួល «*សព្វថ្ងៃនេះម្ចាស់ផ្ទះនេះគឺមិនមានកិច្ចសន្យាអីទេ ហើយប្រសិនបើគេចង់ទារយកបន្ទប់វិញ ខ្ញុំក៏មិនដឹងធ្វើយ៉ាងណាដែរ។ អ្នកខ្លះត្រូវបានគេដេញចេញគេទុកឲ្យសន្តិសុខ និងបងប្អូនរបស់គេនៅ*»។ ទីបី ម្ចាស់ផ្ទះខ្លះ មិនបានផ្តល់ប្រាក់កក់ថៃរក្សាកុងទ័រលើសេវាកម្មភ្ជាប់អគ្គិសនីដល់កម្មការិនីកម្មករវិញទេ បន្ទាប់ពីពួកគាត់នោះឈប់ជួលបន្ទប់របស់ខ្លួន «*កាលមុនប្រាប់ថាពេលចេញ (ឈប់ជួលបន្ទប់) នឹងបង់លុយ ថ្លៃភ្លើងឲ្យខ្ញុំ។ ខ្ញុំកក់ទឹក កក់ភ្លើងឲ្យគេទៀត។ ពេលខ្ញុំចេញគេសន្យាថា នឹងឲ្យលុយកក់វិញ តែពេលចេញគេអត់បង់លុយឲ្យខ្ញុំវិញទេ។ ហើយពេលខ្ញុំទៅយកគេថាខ្ញុំហ្នឹង ពួកវ៉ែងជួលខែគេកម្រិតហើយ។ ដល់ឥឡូវហ្នឹងខ្ញុំអត់បានលុយហ្នឹងទេ*»។

បើយោងតាមច្បាប់ភតិសន្យាពិសេសមាត្រា៥ បានចែងថា ភតិសន្យាពិសេសត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសេចក្តីបញ្ជាក់របស់មេឃុំ ឬចៅសង្កាត់។ ប៉ុន្តែជាក់ស្តែងនៅក្នុងការស្រាវជ្រាវរកឃើញថាកម្មការិនីកម្មករស្ទើរតែ ១០០ភាគរយ ដែលស្នាក់នៅតាមបន្ទប់ជួលមិនទាន់មានកិច្ចសន្យានៅឡើយទេ។ នេះអាចមកពីច្បាប់ពិសេសមួយនេះទើបតែត្រូវបានអនុម័តក្នុងឆ្នាំ២០១៥ ហើយវិសាលភាពក្នុងការផ្សព្វផ្សាយដល់ថ្នាក់មូលដ្ឋាននៅមានកម្រិតនៅឡើយ។ មួយវិញទៀតកម្មការិនីកម្មករហាក់ដូចជាមិនឃើញពីអត្ថប្រយោជន៍នៃកិច្ចសន្យានោះទេ ប៉ុន្តែគិតថាជាការដាក់កម្រិតក្នុងការផ្លាស់ប្តូរបន្ទប់ជួលតាមតម្រូវការរបស់គាត់។

### ៣.១.៦ សេវាកម្មទឹក

កម្មការិនី កម្មករ ៦៩នាក់ ស្មើនឹង ៩២ភាគរយ បានប្រើប្រាស់សេវាទឹកឯកជនដែលធ្វើឲ្យពួកគាត់ត្រូវចំណាយច្រើនក្នុងមួយខែៗ។ សេវាកម្មទឹកមានតម្លៃខុសៗគ្នាទៅតាមការកំណត់របស់ម្ចាស់បន្ទប់ជួល។ ម្ចាស់បន្ទប់ជួលខ្លះបានកំណត់តម្លៃទឹក ១២០០ រៀលក្នុងមួយម៉ែត្រគូប អ្នកខ្លះកំណត់

តម្លៃ២៥០០រៀលក្នុងមួយម៉ែត្រគូប និងខ្លះទៀតរហូតដល់៣០០០រៀលក្នុងមួយម៉ែត្រគូប។ កម្មករនៅតំបន់ចាក់អង្រែក្រោមបានឲ្យដឹងថា៖ *«មួយខែយើងប្រើអស់ ៦ ទៅ ៧ម៉ែត្រគូបតម្លៃ១២០០ រៀលក្នុងមួយម៉ែត្រគូប ហើយបើកាលពីមុនថ្លៃ ២៥០០រៀល»*។

អាជ្ញាធរនៅតំបន់ចាក់អង្រែក្រោម កាលពីដើមឆ្នាំ២០១៦ បានហៅម្ចាស់ផ្ទះជួលទាំងអស់ដើម្បីជជែកពីបញ្ហាតម្លៃទឹកដែលផ្គត់ផ្គង់ទៅឲ្យអ្នកជួលបន្ទប់។ ជាលទ្ធផលអាជ្ញាធរបានតម្រូវឲ្យម្ចាស់ផ្ទះជួលទាំងអស់គិតតម្លៃទឹកត្រឹម១២០០រៀលក្នុងមួយម៉ែត្រគូបទៅដល់អ្នកជួល។ ទោះបីជាមានការយល់ព្រមពីម្ចាស់ផ្ទះជួលក៏ដោយ ប៉ុន្តែការអនុវត្តជាក់ស្តែងម្ចាស់ផ្ទះជួលខ្លះមិនបានធ្វើតាមការព្រមព្រៀងទាំងស្រុងនោះទេ។ ដោយឡែកម្ចាស់បន្ទប់ជួលខ្លះគិតតម្លៃទឹកទៅតាមចំនួនមនុស្សដែលបានជួលបន្ទប់ដោយយកតម្លៃ១ដុល្លារម្នាក់ក្នុងមួយខែ។ កម្មការិនីតំបន់ចាក់អង្រែក្រោមបញ្ជាក់៖ «*ម្ចាស់ផ្ទះគាត់និយាយថា កាលមុនគាត់តភ្លើង ១៥០០រៀល គាត់បានចំណេញថ្លៃភ្លើង ដូច្នេះគាត់មិនយកថ្លៃទឹក(អណ្តូង)ទេ តែឥឡូវគេតភ្លើងរដ្ឋ១គីឡូ ៦០០រៀល គាត់អត់បានស៊ីទេ អញ្ចឹងគាត់យកថ្លៃទឹក ១ដុល្លារ*»។




តម្លៃទឹករដ្ឋមួយម៉ែត្រគូបចន្លោះពី ៥៥០រៀល ទៅ ៧៥០រៀល ក្នុងមួយគ្រួសារមានសមាជិក៣នាក់អាចប្រើប្រាស់ទឹករដ្ឋអស់តម្លៃប្រមាណជា១ម៉ឺនរៀលក្នុងរយៈពេល២ខែ។ ដូច្នេះតម្លៃទឹក ១២០០រៀលក្នុងមួយម៉ែត្រគូប សម្រាប់កម្មករប្រើប្រាស់នៅតែមានតម្លៃខ្ពស់បើធៀបនឹងប្រជាពលរដ្ឋដែលប្រើប្រាស់ទឹករដ្ឋ។

### ៣.១.៧ សេវាកម្មអគ្គិសនី

តាមការសិក្សាបានឲ្យដឹងថា មានកម្មការិនីកម្មករ ៨៩,២ភាគរយ បានប្រើប្រាស់សេវាអគ្គិសនីរដ្ឋ និង១០,៨ភាគរយ បានប្រើសេវាអគ្គិសនីឯកជន(តភ្លើងពីម្ចាស់ផ្ទះជួល)។

នៅដើមឆ្នាំ២០១៥ អគ្គិសនីកម្ពុជាបានចេញសេចក្តីប្រកាសព័ត៌មានស្តី *ពីវិធានការបន្ត សម្រាប់ផ្ទះជួល ឬបន្ទប់ជួលក្នុងតំបន់ចែកចាយផ្ទាល់របស់អគ្គិសនីនៅរាជធានីភ្នំពេញ* ផ្អែកតាមការស្រាវជ្រាវនេះ ឃើញថាម្ចាស់ផ្ទះជួលជិត ៩០ភាគរយ បានអនុវត្តតាមសេចក្តីប្រកាសនេះដោយអនុញ្ញាតឲ្យអគ្គិសនី

កម្ពុជាតបណ្ដាញចូលតាមបន្ទប់ជួលរបស់កម្មការិនី កម្មករនីមួយៗដោយគិតតម្លៃ ៦១០រៀល ក្នុងមួយគីឡូវ៉ាត់។ ទោះបីជាយ៉ាងណាក៏ដោយប្លុកមួយចំនួនដែលមានបន្ទប់ជួលក្រោម១០បន្ទប់ អគ្គិសនីកម្ពុជាមិនបានតបណ្ដាញចូលនោះទេដោយមូលហេតុមានចំនួនបន្ទប់តិចពេក ម្យ៉ាងមានម្ចាស់បន្ទប់មួយចំនួនក៏មិនបានសហការ ឬមិនអនុញ្ញាតឲ្យមន្ត្រីអគ្គិសនីកម្ពុជាតបណ្ដាញដល់បន្ទប់របស់កម្មការិនី កម្មករនោះទេ។ ត្រង់ចំណុចនេះបង្ហាញឲ្យឃើញថា អគ្គិសនីកម្ពុជាក៏នៅមិនទាន់ពង្រីកបណ្ដាញដល់គ្រប់បន្ទប់របស់កម្មការិនី កម្មករនៅឡើយទេ។

### ៣.១.៨ បរិក្ខាបន្ទប់ជួល និងការជួសជុលបន្ទប់

តាមការសិក្សាបានបង្ហាញថាកម្មការិនីកម្មករចំនួន ៤២ភាគរយ ម្ចាស់បន្ទប់ជួលបានផ្ដល់គ្រែឲ្យមួយ។ បន្ថែមពីនេះក៏មានម្ចាស់បន្ទប់ខ្លះបានផ្ដល់សម្ភារៈដូចជា កន្ទេល ធុងទឹក ធុងសំរាមជាដើម ហើយ ២១ភាគរយ ម្ចាស់បន្ទប់ជួលមិនបានផ្ដល់សម្ភារៈអ្វីទាំងអស់មានត្រឹមតែបន្ទប់ទទេតែប៉ុណ្ណោះ។

កម្មការិនី កម្មករ ៧៩,៥ភាគរយ និយាយថាម្ចាស់បន្ទប់ជួលជាអ្នកទទួលរ៉ាប់រងក្នុង ការជួសជុលនៅពេលដែលបន្ទប់ជួលរងនូវការបែកបាក់ ឬខូចខាត។ ជាទូទៅម្ចាស់បន្ទប់ជួលបានជួសជុលដូចជាដំបូលធ្លុះធ្លាយ ជ្រាបទឹក ទ្វារបន្ទប់ខូច និងមានស្នាមជញ្ជាំងប្រេះជាដើម។ ទោះជាម្ចាស់បន្ទប់ជួលជាអ្នកទទួលរ៉ាប់រង រាល់ការជួសជុលបន្ទប់យ៉ាងណាក៏ដោយក៏នៅតែជាបញ្ហាសម្រាប់ អ្នកជួលបន្ទប់ ព្រោះត្រូវរង់ចាំយូរថ្ងៃទើបទទួលបានការឆ្លើយតបនិងចុះទៅត្រួតពិនិត្យ មុនពេលយល់ព្រមក្នុងការជួសជុល ហើយក៏ត្រូវរង់ចាំបន្តទំរាំហូតមានអ្នកមកជួសជុល។ អាស្រ័យហេតុនេះ កម្មការិនី កម្មករភាគច្រើនសម្រេចចិត្តក្នុងការជួសជុលបន្ទប់ ឬទិញសម្ភារៈដោះដូរដោយខ្លួនឯង។

សម្ភារៈផ្គត់ផ្គង់តាមបន្ទប់ជួល




គិតជាភាគរយក្នុងចំណោម៧៩នាក់

### ៣.១.៩ បំពង់ពន្លត់អគ្គីភ័យក្នុងអគារ

កម្មការិនី កម្មករ ៨៣,៨ភាគរយ បានឆ្លើយថា ប្លុកបន្ទប់ជួលរបស់គាត់គ្មានបំពង់ពន្លត់អគ្គីភ័យនោះទេ ហើយ ១៦,២ភាគរយ បានឲ្យដឹងថាប្លុកបន្ទប់ជួលរបស់គាត់មានបំពង់ពន្លត់អគ្គីភ័យ។

ចំពោះប្លុកជួលដែលមានបំពង់ពន្លត់អគ្គីភ័យ កម្មការិនីកម្មករបានអះអាងថា បំពង់ពន្លត់អគ្គីភ័យទាំងនោះភាគច្រើនដាក់នៅផ្ទះម្ចាស់បន្ទប់ជួល និងកន្លែងគិតលុយ ហើយមានចំនួនចន្លោះពី១ ដល់៤ បំពង់ពន្លត់អគ្គីភ័យ។ នៅតាមប្លុកជួលនីមួយៗមានកម្មករជួលបន្ទប់រស់នៅច្រើន ដែលទាមទារឲ្យម្ចាស់បន្ទប់ជួលគិតគូរពីសុវត្ថិភាពរបស់ពួកគាត់ តាមរយៈបំពាក់បំពង់ពន្លត់អគ្គីភ័យឲ្យបានគ្រប់គ្រាន់នៅតាមបន្ទប់ជួលនីមួយៗ និងត្រូវបង្រៀនពីរបៀបប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ ដើម្បីការពារហានិភ័យដែលអាចកើតឡើងដោយថាហេតុ។

# មតិយោបល់ និងអនុសាសន៍

យោងទៅតាមការស្រាវជ្រាវ បានបង្ហាញថាការរស់នៅ និងការទទួលបានសេវាសង្គមជាមូលដ្ឋានរបស់កម្មការិនី កម្មករ មិនទាន់បានធានា ឬទទួលបានការការពារពេញលេញដូចមានចែងក្នុងគោលនយោបាយ និងច្បាប់ជាតិនានាៗ ទោះបីជាពួកគាត់បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារយ៉ាងណាក៏ដោយ។ ក្នុងការលើកកំពស់ និងរួមចំណែកធ្វើឲ្យការរស់នៅរបស់កម្មការិនីកម្មករប្រកបដោយសេចក្ដីថ្លៃថ្នូរ ក្រុមអ្នកស្រាវជ្រាវរួមជាមួយកម្មការិនី កម្មករ ដែលបានចូលរួមក្នុងដំណើរសិក្សាស្រាវជ្រាវបានលើកជាមតិយោបល់ និងអនុសាសន៍ជាក់លាក់សម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗដូចខាងក្រោម៖

<u>រាជរដ្ឋាភិបាលកម្ពុជា</u>

- ត្រូវយកចិត្តទុកដាក់ដល់ការការពារជំងឺ និងការព្យាបាលប្រកបដោយគុណភាព និងវិជ្ជាជីវៈ។
- ទប់ស្កាត់ និងត្រួតពិនិត្យអាហារគ្រប់ប្រភេទដែលមានសារជាតិគីមីដែលចរាចរនៅលើទីផ្សារ ដើម្បីធានាថាប្រជាពលរដ្ឋមានសុខភាពល្អ។
- អាជ្ញាធរមូលដ្ឋានត្រូវតែដោះស្រាយបន្ទាន់ក្នុងករណីមានការរាយការណ៍ពីម្ចាស់បន្ទប់ជួល ឬអ្នកជួលពាក់ព័ន្ធសន្តិសុខ និងសុវត្ថិភាពដែលកើតឡើងនៅក្នុងតំបន់គ្រប់គ្រងរបស់ខ្លួន។
- ត្រូវមានពេទ្យចល័ត ឬការគាំទ្រដឹកជញ្ជូន និងធ្វើកិច្ចសន្យាជាមួយគ្លីនិក ឬឱសថស្ថានណាដែលនៅជិតកន្លែងធ្វើការ និងកន្លែងរស់នៅរបស់កម្មការិនី កម្មករ។
- អាជ្ញាធរមូលដ្ឋានបង្កើតទំនាក់ទំនងឲ្យបានជិតស្និតជាមួយកម្មការិនីកម្មករតាមរយៈការហៅឲ្យចូលរួមប្រជុំវេទិកាសាធារណៈ និងសកម្មភាពផ្សេងៗដែលមាននៅតាមឃុំសង្កាត់។
- ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងអនុវត្តឲ្យមានប្រសិទ្ធិភាពទៅលើគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព និងចាត់វិធានការយ៉ាងមុងម៉ាត់ចំពោះករណីបំពានដែលកើតមានឡើង។
- ផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធិភាពទៅលើច្បាប់ភតិសន្យាពិសេស។ ដោយធ្វើឲ្យប្រាកដថាម្ចាស់ផ្ទះ/បន្ទប់ជួលអ្នកជួលទទួលបានការយល់ដឹងពីកិច្ចសន្យារយៈពេលនៃការឡើងថ្លៃបន្ទប់ស្តង់ដាបន្ទប់ជួល និងតម្លៃ។
- ជំរុញឲ្យនិយោជកទាំងអស់រួមចំណែកក្នុងការរៀបចំលំនៅឋាន ឬកន្លែងស្នាក់នៅសមរម្យសម្រាប់កម្មការិនីកម្មករគ្រប់កន្លែង ដោយធានាថាកន្លែងស្នាក់នៅនោះត្រឹមត្រូវតាមស្តង់ដារមានប្រព័ន្ធទឹកស្អាត អគ្គិសនី មានអនាម័យ និងបរិស្ថានល្អ។
- អាជ្ញាធរមូលដ្ឋានចាត់វិធានការបង្ក្រាបរាល់ល្បែងស៊ីសងគ្រប់ប្រភេទ ដែលប្រព្រឹត្តនៅតាមតំបន់គ្រប់គ្រងរបស់ខ្លួន។

- មន្ត្រីអគ្គិសនីកម្ពុជា រួមទាំងអាជ្ញាធរដែនដីត្រូវពង្រីក បណ្តាញតភ្ជាប់តាមបន្ទប់ជួលឲ្យបានគ្រប់តំបន់និងបន្ទប់។ ហើយដាក់កំហិតដល់ម្ចាស់ផ្ទះឬបន្ទប់ជួលទាំងឡាយណាដែលមិនអនុវត្តតាមសេចក្តីប្រកាសព័ត៌មានស្តីពីវិធានការបន្តសម្រាប់ផ្ទះជួលឬបន្ទប់ជួលក្នុងតំបន់ចែកចាយផ្ទាល់របស់អគ្គិសនីនៅរាជធានីភ្នំពេញ។
- គួរតែចេញសេចក្តីប្រកាសក្នុងការតបណ្តាញទឹករដ្ឋដល់បន្ទប់ជួលកម្មការិនី កម្មករ ឲ្យបានឆាប់រហ័សដូចការតបណ្តាញអគ្គិសនី។

<u>ម្ចាស់ផ្ទះឬបន្ទប់ជួល</u>

- គួរសង់អគារដែលមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់អ្នកជួល។ ប្រសិនបើសង់បន្ទប់ទឹក ឬបង្គន់រួមត្រូវមានអនាម័យ និងសុវត្ថិភាពដោយមានការបិទបាំងត្រឹមត្រូវដើម្បីរក្សាភាពឯកជនក្នុងពេលប្រើប្រាស់។
- គួរសង់បង្គន់ បន្ទប់ទឹក និងដាក់លូ ឬបំពង់បង្ហូរ កាកសំណល់ និងទឹកដែលប្រើប្រាស់រួចឲ្យសមាមាត្រជាមួយចំនួនអ្នកជួលបន្ទប់ ដើម្បីជៀសវាងការកកស្ទះ ឬបង្ហៀរកាកសំណល់លើទីសាធារណៈដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាននិងសុខភាពដល់អ្នករស់នៅ។
- អគារបន្ទប់ជួលគួរទុកចន្លោះសមស្របសម្រាប់ដើរ និងទីវាលសំរាប់ហាលខោអាវ ដើម្បីជានាផាសុកភាព មានខ្យល់ និងមានពន្លឺគ្រប់គ្រាន់។
- ទទួលខុសត្រូវលើសន្តិសុខ និងសុវត្ថិភាពរបស់អ្នកជួល តាមរយៈការដាក់សន្តិសុខយាម ២៤ ម៉ោង និងរឹតបន្តឹងលើការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនយ៉ាងម៉ត់ចត់។
- សហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីអន្តរាគមន៍រាល់ករណីលួចគាស់បន្ទប់ ឬការរំខាននានាដែលបានកើតឡើងក្នុងតំបន់ជួលរបស់ខ្លួន។
- ពិនិត្យលើឯកសារ (អត្តសញ្ញាណបណ្ណ សៀវភៅគ្រួសារ និងសំបុត្រការងារជាដើម) របស់អ្នកជួលឲ្យបានច្បាស់លាស់ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងផ្តល់សុវត្ថិភាពដល់អ្នកជួលបន្ទប់។
- ស្វែងយល់ និងអនុវត្តតាមច្បាប់ភតិសន្យាពិសេស សេចក្តីប្រកាសព័ត៌មានស្តីពីវិធានការបន្តសម្រាប់ផ្ទះជួល ឬបន្ទប់ជួលក្នុងតំបន់ចែកចាយផ្ទាល់របស់អគ្គិសនីនៅរាជធានី ភ្នំពេញ ។

<u>កម្មការិនី កម្មករ</u>

- ស្វែងយល់ព័ត៌មាន និងពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយទាំងបរិយាកាសបន្ទប់ ការប្រើប្រាស់សេវាទឹកភ្លើង និងច្រកសុវត្ថិភាពមុននឹងសម្រេចចិត្តជួលបន្ទប់ស្នាក់នៅ។

- ត្រូវយល់ដឹងពីសុខភាព អនាម័យ និងសុវត្ថិភាពចំណីអាហាររបស់ខ្លួន និងអនុវត្តឲ្យបានខ្ជាប់ខ្ជួន។
- បង្កើតទំនាក់ទំនងឲ្យបានជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន និងស្វែងយល់ឲ្យបានច្បាស់ពីរបៀបរាយការណ៍នៅពេលមានបញ្ហាកើតឡើងពាក់ព័ន្ធសន្តិសុខ និងសុវត្ថិភាពរបស់ខ្លួន។ ជាពិសេសគួររាយការណ៍នៅពេលខ្លួនជួបការបៀតបៀនកេរ្តិ៍ខ្មាស់។
- ចូលរួមរាយការណ៍ និងទប់ស្កាត់រាល់ការលេងល្បែងស៊ីសង និងប្រើប្រាស់គ្រឿងញៀនដែលប្រព្រឹត្តក្នុងតំបន់ស្នាក់នៅរបស់ខ្លួន។
- ត្រូវស្វែងយល់ពីគោលនយោបាយផ្សេងៗ ដែលគាំពារដល់ការរស់នៅប្រកបដោយសុវត្ថិភាព។
- សហការជាមួយកម្មការិនី កម្មករ ផ្សេងទៀតនៅតំបន់របស់ខ្លួនក្នុងការរក្សាអនាម័យ (ទាំងចំណីអាហារ និងកន្លែងរស់នៅ) ការទុកដាក់សំរាម កាកសំណល់ និងសំអាតបរិស្ថានជុំវិញឲ្យបានប្រសើរ។

<u>ថៅកែរោងចក្រ និងម្ចាស់ផ្ទះ</u>

- ពិចារណាទៅលើផាសុកភាព និងសុវត្ថិភាពរបស់កម្មការិនី កម្មកររោងចក្រកាត់ដេរ ដោយធ្វើឲ្យប្រាកដថាអ្នកទាំងនោះមានកន្លែងរស់នៅសមរម្យ ទទួលទានអាហារមានជីវជាតិប្រកបដោយអនាម័យនិងសុវត្ថិភាព។

# ជញ្ជាំងផ្ទះឆ្ងាយ

នៅតាមបណ្ដោយផ្លូវវេងស្រេង សម្បូរដោយអគារធំៗនៅអមសងខាងផ្លូវដែលអគារទាំងនោះជាបណ្ដុំនៃរោងចក្រកាត់ដេរ។ កន្លែងណាដែលមានរោងចក្រ កន្លែងនោះក៏តែងតែមានបន្ទប់ជួលសម្រាប់កម្មការិនីកម្មករផងដែរ។

តាមផ្លូវនេះដែរ ត្រង់ចំណុចភូមិត្រពាំងថ្លឹង មានបន្ទប់ជួលមួយប្លុកបានសាងសង់ជាប់នឹងរបងរោងចក្រតែម្ដង។ ប្រសិនបើមើលពីខាងក្រៅហាក់ដូចជាមើលមិនដឹងថាមានបន្ទប់ជួលរបស់កម្មករនៅខាងក្នុងនោះទេ ព្រោះនៅចំពីមុខផ្លូវចូលម្ចាស់ផ្ទះជួលបានសាងសង់របងធ្វើពីថ្ម និងទ្វារធ្វើពីដែកកម្ពស់ប្រហែលបីម៉ែត្រព័ទ្ធពីខាងក្រៅ។

នៅពេលដើរឆ្លងកាត់ទ្វារនេះ នៅខាងស្ដាំដៃមានបន្ទប់ជាច្រើនសង់ជាប់ៗគ្នាជាជួរៗ រីឯនៅខាងឆ្វេងដៃវិញមានតូបលក់បាយម្ហូបប្រហែលជា ១០តូប ហើយតូបទាំងនោះធ្វើបែរមុខមកបន្ទប់ជួល។ នៅក្បែរតូបលក់បាយមានគំនរសំរាមស្អុយរលួយធំមួយគំនរ ហើយនៅជាប់នឹងបង្គន់។

បន្ទប់ជួលនៅក្នុងប្លុកនេះមានប្រមាណជា៦ជួរ។ បន្ទប់៣ជួរបានសាងសង់ពីឈើប្រក់ស័ង្កសីដែលមានសភាពទ្រុឌទ្រោម ហើយបន្ទប់ជួល៣ជួរទៀតសាងសង់ពីឥដ្ឋបូកស៊ីម៉ង់ត៍ពីខាងក្រៅ។ ចំនួនសរុបទាំងអស់នៅក្នុងប្លុកនេះមានប្រហែលជាជាង៣០០បន្ទប់។



បន្ទប់ជួលដែលសាងសង់ពីឥដ្ឋបូកស៊ីម៉ង់ត៍មានទំហំ ២ម៉ែត្រគុណ៣ម៉ែត្រ ដែលអាចដាក់គ្រែបានមួយនិងមានចាក់កម្រាលស៊ីម៉ង់ត៍ ហើយមានតម្លៃ២០ដុល្លារក្នុងមួយខែ។ ដោយឡែកបន្ទប់ដែលសាងសង់ពីឈើមានទំហំធំជាងបន្ទប់ថ្ម ព្រោះអាចដាក់គ្រែបានពីរ និងមានចាក់កម្រាលស៊ីម៉ង់ត៍ដូចគ្នាមានតម្លៃ ២៥ដុល្លារ ក្នុងមួយខែ។ ក្នុងបន្ទប់ជួលនីមួយៗមានអ្នករស់នៅចន្លោះពីពីរនាក់ទៅបួន

នាក់។ ចំពោះការបង់ថ្លៃបន្ទប់ជួល អ្នកជួលមិនអាចបង់លើសមួយថ្ងៃពីថ្ងៃកំណត់បានឡើយ ប្រសិនបើអ្នកជួលបង់ថ្លៃបន្ទប់លើសមួយថ្ងៃម្ចាស់ផ្ទះជួលនឹងទៅទារដល់មុខបន្ទប់ដោយប្រើពាក្យសម្ដីមិនសមរម្យ។

នៅពីមុខជួរបន្ទប់ជួលនីមួយៗមានចង្អូរទឹកមួយសម្រាប់បង្ហូរទឹក អ្នកជួលមួយចំនួនបានបោះកាកសំណល់ចោលតាមចង្អូរទឹកនេះផងដែរ។



រាល់ពេលមានភ្លៀងធ្លាក់ តែងតែមានការស្ទះលូ ហើយទឹកបានហូរចូលក្នុងបន្ទប់ទាំងនោះ រួមទាំងកាកសំណល់ និងសំរាមផ្សេងៗ ក៏ហូរទៅជាមួយទឹកចូលបន្ទប់ផងដែរ។ ដើម្បីការពារទឹកលិច សម្ភារៈនៅក្នុងបន្ទប់អ្នកជួល បន្ទប់ខ្លះបានប្រើប្រាស់ដុំឥដ្ឋ ដើម្បីធ្វើជាកំណល់សម្រាប់ដាក់ទ្រសម្ភារៈពីខាងក្រោម។ បើនៅរដូវក្ដៅវិញ ក្នុងបន្ទប់មានសភាពក្ដៅខ្លាំងពិបាកក្នុងការរស់នៅជាពិសេសនៅពេលថ្ងៃ។

ដោយសារប្លុកបន្ទប់ជួលសាងសង់ឡើងនៅជាប់នឹងរោងចក្រ បណ្ដាលឲ្យអ្នកជួលបន្ទប់ទទួលរងការរំខានពីសំឡេងម៉ាស៊ីនក្នុងរោងចក្រ។ ទន្ទឹមនឹងនេះដែរ កំទេចក្រណាត់រោងចក្របានហុយពាសពេញបន្ទប់ជួល ជាពិសេសហុយចូលពាងទឹកនៅមុខបន្ទប់ជួលដែលមិនមានគម្រប។

ប្លុកជួលនេះដែរមិនទាន់មានការតបណ្ដាញអគ្គិសនីកម្ពុជានៅឡើយទេ ដូច្នេះអ្នកជួលបន្ទប់ត្រូវប្រើប្រាស់ភ្លើងដែលតមកពីម្ចាស់បន្ទប់ជួលដែលភ្លើងនោះមានតម្លៃ ២៥០០រៀលក្នុងមួយគីឡូវ៉ាត់។ ដោយឡែកអ្នកជួលបន្ទប់ខ្លះទៀតបានតបណ្ដាញអគ្គិសនីនេះពីអ្នកជួលបន្ទប់ផ្សេងទៀត ហើយគាត់ត្រូវចំណាយប្រហែល ២០០០០រៀល ទៅ៣០០០០រៀលក្នុងមួយខែ។

តាមមុខបន្ទប់ជួលនីមួយៗមានពាងសម្រាប់ដាក់ទឹកដើម្បីចម្អិនអាហារ បោកគក់សម្លៀក និងងូតជាដើម។ អ្នកជួលបន្ទប់ត្រូវទិញទឹកក្នុងតម្លៃ ១៥០០រៀលក្នុងមួយពាង។ ក្នុងមួយខែអ្នកជួលបន្ទប់

ដែលមានមនុស្សស្នាក់នៅពីរនាក់បានប្រើប្រាស់ទឹកអស់ប្រហែល៧ ទៅ៨ពាង។ ដោយឡែកនៅរដូវវស្សាពួកគេប្រើប្រាស់ទឹកអស់ប្រហែល ៤ទៅ ៥ពាង។ ទឹកដែលលក់ឲ្យអ្នកជួលបន្ទប់នេះបានបង្ហូរពីស៊ីទែនធំមួយដែលមានសភាពច្រេះចាប់ ដែលទំនងជាប្រើប្រាស់រយៈពេលយូរឆ្នាំមកហើយ។ រីឯបំពង់បង្ហូរទឹកទៀតសោតមានស្លែរកាន់ ដោយអន្លើ។

ប្លុកជួលនេះមិនមានបន្ទប់ទឹកក្នុងបន្ទប់ជួលនោះទេ។ អ្នកជួលបានប្រើប្រាស់ទីតាំងដាក់ពាងទឹកមុខបន្ទប់ជួលធ្វើជាកន្លែងងូតទឹក។ ការងូតទឹកដែលគ្មានកន្លែងបិទបាំងធ្វើឲ្យអ្នកជួលបន្ទប់ជាពិសេសស្ត្រីពិបាកក្នុងការសម្អាតរាងកាយឲ្យបានស្អាតបាត។

ចំពោះបង្គន់អនាម័យវិញមានប្រមាណ ១៦បង្គន់ ដែលអ្នកជួលបន្ទប់ជាង ៣០០ បន្ទប់នោះត្រូវប្រើប្រាស់រួមគ្នា។ បង្គន់អនាម័យទាំងនោះមានទំហំប្រហែល ១ម៉ែត្រគុណ១ម៉ែត្រ និងមានសភាពចាស់ទ្រុឌទ្រោម ហើយក្នុងចំណោមបង្គន់ទាំង១៦នោះ មានបង្គន់ប្រហែល ៣ទៅ ៤បង្គន់ ស្ទះលូខូចប្រើប្រាស់លែងកើត។ បង្គន់ទាំងនោះមានចាក់កម្រាលស៊ីម៉ង់ត៍ និងដំបូលប្រក់ស័ង្កសីធ្លុះធ្លាយ ហើយនៅពេលមានភ្លៀងធ្លាក់តែងមានទឹកលិច និងស្រក់ធ្លាក់តាមដំបូល។ ក្នុងបង្គន់នេះដែរមានអាងទឹកខាងក្នុងដែលមានកម្ពស់ប្រហែល ៤តឹក ហើយជារឿយៗមានកណ្តុរងាប់ក្នុងអាងនោះ។ នៅក្នុងបង្គន់ទាំងនេះពេលខ្លះមានលាមក និងសំឡីអនាម័យដែលបោះចោលមិនបានត្រឹមត្រូវ ព្រោះក្នុងនោះមិនមានធុងសំរាម។ ទន្ទឹមនឹងនេះដែរ នៅក្នុងនោះគ្មានសាប៊ូសម្រាប់ប្រើប្រាស់នោះទេ ហើយរយៈពេល ១សប្តាហ៍ទៅ ២សប្តាហ៍ ទើបមានការសម្អាតម្តង បណ្តាលឲ្យបង្គន់នេះមានក្លិនស្អុយ និងរុយរោម។




បន្ទប់ជួលនៅក្នុងប្លុកមានទ្វារធ្វើពីបន្ទះក្តារ បានបង្ករភាពងាយស្រួលសម្រាប់ចោរក្នុងការគាស់បន្ទប់។ អ្នកជួលបន្ទប់មិនហ៊ានទុកវត្ថុមានតម្លៃនៅក្នុងបន្ទប់នោះទេ។ ដោយឡែកសម្រាប់ករណីលួចវិញ មានភាពញឹកញាប់ជាងករណីគាស់បន្ទប់។ ដោយសារតែបន្ទប់តូចចង្អៀត និងមិនមានកន្លែង

ហាលខោអាវត្រឹមត្រូវ អ្នកជួលបន្ទប់បានហាលសម្លៀកបំពាក់នៅខាងមុខបន្ទប់ ហើយជារឿយៗពួកគាត់បានបាត់ខោអាវ និងស្បែកជើង។

បញ្ហាល្បែងស៊ីសងតែងកើតមានស្ទើរតែគ្រប់ប្លុកជួលកម្មការិនីកម្មកររោងចក្រ។ ប្លុកនេះក៏មិនខុសគ្នាដែរ អ្នកជួលបន្ទប់ភាគច្រើននៅពេលល្ងាចដែលទំនេរពីការងារ ពួកគេនាំគ្នាលេងអាប៉ោង បៀរ និងខ្លាឃ្លោក រហូតដល់ម៉ោងមួយ ម៉ោងពីរទៀបភ្លឺ។ ទោះបីជាមានបទបញ្ញត្តិផ្ទៃក្នុង និងការហាមប្រាមពីម្ចាស់ផ្ទះជួលក៏ដោយ ក៏សកម្មភាពលេងល្បែងស៊ីសងនេះនៅតែកើតមានស្ទើររៀងរាល់ថ្ងៃ។

កម្មករនៅក្នុងប្លុកនេះក៏បានឲ្យដឹងផងដែរថា ប្លុកនេះក៏មានការប្រើប្រាស់គ្រឿងញៀនដែរ។ ពួកគេប្រើប្រាស់គ្រឿងញៀននៅក្នុងបន្ទប់ទឹកនៅម៉ោងប្រហែលជា ៣ ទៅ ៤ទៀបភ្លឺ៕

# ផ្នែកទី៤

## ឯកសារយោង និងឧបសម្ព័ន្ធ

# ឯកសារយោង


១. ផែនការណែនាំលេខ ០២០ ផក របស់ក្រសួងមហាផ្ទៃ ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។

២. Strategic Framework for Health Financing 2008-2015 of Bureau of Health Economics and Financing Department of Planning & Health Information on April 2008.

៣. គោលនយោបាយជាតិ ស្តីពីលំនៅឋាន ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤។

៤. ច្បាប់ភតិសន្យាពិសេសៈ ត្រូវបានអនុម័តដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៥នាសម័យប្រជុំរដ្ឋសភានីតិកាលទី៥។

៥. សេចក្តីប្រកាសព័ត៌មាន**លេខ០៤៩២ អកលខ** ស្តីពីវិធានការបេន្ត សម្រាប់ផ្ទះជួល ឬបន្ទប់ជួលក្នុងតំបន់ចែកចាយផ្ទាល់របស់អគ្គីសនីកម្ពុជានៅរាជធានីភ្នំពេញ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥។

## ការទាមទារ

រៀបចំប៉ុស្តិ៍យាម កម្លាំងការពារ និង ភ្លើងបំភ្លឺផ្លូវនៅម្តុំបន្ទប់ជួល

ដាក់បន្ថែមកម្លាំងការពារ

អាជ្ញាធរធ្វើតាមតួនាទី និង មានក្រមសីលធម៌

ជំរុញអោយមានវេទិការសាធារណៈ នៅតាមមូលដ្ឋានប្រចាំត្រីមាស

មានប្រព័ន្ធរាយការណ៍ និងទទួលពាក្យបណ្តឹងដោយគ្មានការរើសអើង និង យុត្តិធម៌

ផ្តល់សេវាអប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ធានាការគោរពសិទ្ធិប្រកបរបរចិញ្ចឹមជីវិតដោយគ្មានការរើសអើង

ពិនិត្យ និង ធ្វើវិសោធនកម្មច្បាប់ «ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ» ដែលបញ្ឈប់ការរឹតត្បិតសិទ្ធិសេរីភាព ឬ ដាក់ទោសអ្នកលក់សេវា

## ដំណោះស្រាយ



# គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព

## ចំណុចវិជ្ជមាន

- មានការកំណត់ពីលក្ខណសម្បត្តិភូមិឃុំមានសុវត្ថិភាពទាំង៥ [1]
- នគរបាលប៉ុស្តិ៍រដ្ឋបាលត្រូវរៀបចំឱ្យមានក្របខណ្ឌគ្រប់ចំនួនតាមកន្លែង និងប្រជាជន និងមានកំលាំងប្តូរវេនប្រចាំការ
- រដ្ឋបាលឃុំសង្កាត់ត្រូវសម្របសម្រួលឱ្យមានវេទិកាសាធារណៈស្តីពី សុវត្ថិភាពភូមិឃុំ យ៉ាងតិច១ដងក្នុងរយៈពេល៣ខែ ដោយត្រូវដោះស្រាយសំណើ និងសំណូមពរនានារបស់ប្រជាពលរដ្ឋ

United Sisterhood Alliance

## ចំណុចខ្វះខាត

- មិនទាន់មានការផ្សព្វផ្សាយទូលំទូលាយពីគោលនយោបាយនិងវេទិកាសាធារណៈ ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន
- មិនមានភ្លើងបំភ្លឺតាមផ្លូវ និងនៅតាមតំបន់បន្ទប់ជួល គ្រប់គ្រាន់ដើម្បីធានាសុវត្ថិភាព
- ស្ត្រីប្រកបរបរផ្លូវភេទរងការចាប់ខ្លួនពីប៉ូលីស និងកងសន្តិសុខនៅទីសាធារណៈ
- ដំណោះស្រាយពាក្យបណ្តឹង និងអន្តរាគមន៍ពីអាជ្ញាធរនៅមានកម្រិត និងគ្មានសមត្ថភាព

[1] លក្ខណៈសម្បត្តិភូមិ ឃុំ មានសុវត្ថិភាពទាំង៥យ៉ាងរួមមាន៖

១. គ្មានសកម្មភាពលួច ឆក់ ប្លន់ គ្រប់ប្រភេទ
២. គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់
៣. គ្មានអំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
៤. គ្មានក្មេងទំនើង
៥. គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ

<u>ទូរស័ព្ទទំនាក់ទំនង</u> ៖ +៨៥៥ ១៧ ២២៩ ៥០០ និង +៨៥៥ ៧៨ ៦៥៧ ៥៣១

# សេវាសុខាភិបាល



• កំណត់តម្លៃទាប បង្ហាញ និងអនុវត្តតាមតារាងតម្លៃ
• យកចិត្តទុកដាក់ព្យាបាល ពិនិត្យ និងថែទាំសុខភាព
•បង្កើនសេវាពិគ្រោះយោបល់
•រៀបចំពេទ្យចល័តទូទាំងប្រទេស
•បង្កើនគ្រូពេទ្យគ្រប់ជំនាញ គ្រប់កំរិត
•ត្រួតពិនិត្យការលក់ និងចែកចាយថ្នាំរបស់រដ្ឋ និងឯកជនលើ គុណភាព និង តម្លៃ
• បង្កើនការស្រាវជ្រាវ និង ការផលិតថ្នាំក្នុងស្រុកមានតម្លៃទាប
• បង្កើនប្រាក់ទិញថ្នាំ សំភារៈបរិក្ខាពេទ្យឆ្លើយតបនឹងតម្រូវការ
• គោរពគោលការណ៍មិនរើសអើងអ្នកជំងឺ
• ពង្រឹង និងរឹតបណ្តឹងក្រមសីលធម៌វិជ្ជាជីវៈពេទ្យគ្រប់គ្រឹះស្ថានសិក្សាសុខាភិបាល
• ពង្រឹងយន្តការត្រួតពិនិត្យ និងគ្រប់គ្រងបុគ្គលិក ពេទ្យរដ្ឋ និងឯកជន
• អនុវត្តការពិន័យ និងដាក់ទោសទណ្ឌប្រកបដោយប្រសិទ្ធិភាព
•បង្កើតយន្តការទទួលពាក្យបណ្តឹង និងដោះស្រាយដោយយុត្តិធម៌ និង ឥតបង់ថ្លៃដល់ជនរងគ្រោះ
• ផ្តល់បណ្ណក្រីក្រដោយតម្លាភាព និង ប្រសិទ្ធិភាពដល់ស្ត្រី គ្រប់វិស័យ (កម្មករកាត់ដេរនិង ស្ត្រីប្រកបរបរផ្លូវភេទ)
• ទទួលព្យាបាលជនក្រីក្រដោយយកចិត្តទុកដាក់ និងមានគុណភាព
•បង្កើនកម្មវិធីមូលនិធិសមធម៌គ្រប់ មន្ទីរពេទ្យ និង គ្រប់កំរិត
•បញ្ចូលការអប់រំសុខភាពក្នុង កម្មវិធីសិក្សាជាតិ និង ឯកជនចាប់ពីកម្រិតបឋម
• បង្កើនកម្មវិធីអប់រំ និងផ្សព្វផ្សាយគ្រប់ប្រព័ន្ធសារព័ត៌មាន
•រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលសហការចុះអប់រំសុខភាពពលរដ្ឋដល់មូលដ្ឋាន
• ត្រួតពិនិត្យ និងតាមដានសេវាឯកជនជាប្រចាំប្រកបដោយតម្លាភាព
• ដាក់ពិន័យ និងទោសទណ្ឌគ្រឹះស្ថានឯកជនដែលល្មើសច្បាប់
•បង្កើនកញ្ចប់ថវិកាជាតិដល់វិស័យសុខាភិបាលជាអាទិភាព (ប្រាក់ខែ និងសេវា)
• ពង្រឹងប្រព័ន្ធប្រមូលចំណូលរដ្ឋដើម្បីបង្កើនការចំណាយផ្នែកសុខាភិបាលជាអាទិភាព
• សិក្សាស្រាវជ្រាវពីស្ថានភាពជីវភាពរស់នៅនិងស្ថានភាព សុខភាព របស់ប្រជាពលរដ្ឋ និងមន្ត្រីសុខាភិបាលដោយតម្លាភាពនិងប្រសិទ្ធិភាព
• ប្រើប្រាស់លទ្ធផលសិក្សាស្រាវជ្រាវជាមូលដ្ឋានរៀបចំគោលនយោបាយឆ្លើយតបតាមតម្រូវការពលរដ្ឋពិតប្រាកដនិងជាអាទិភាព (ថវិកាលើប្រាក់ខែ និងសេវា)

គុណភាពសេវា



ថ្នាំ សម្ភារៈ បរិក្ខារ



វិន័យ និង ក្រមសីលធម៌វិជ្ជាជីវៈ



ផ្សព្វផ្សាយ និង អប់រំ




លើកលែងការបង់ថ្លៃសម្រាប់អ្នកក្រ



គ្រប់គ្រងប្រតិបត្តិការពេទ្យឯកជន



តម្លើងប្រាក់ខែបុគ្គលិកសុខាភិបាល




គោលនយោបាយសុខភាពឆ្លើយតបតម្រូវការ



# គោលនយោបាយហិរញ្ញប្បទានសុខាភិបាល

## ចំណុចវិជ្ជមាន

- គ្រឹះស្ថានសាធារណរដ្ឋបាលឱ្យមន្ទីរពេទ្យមានសិទ្ធិកំណត់តម្លៃព្យាបាល គ្រប់គ្រង និងសម្រេចថវិកាលើបុគ្គលិក សម្ភារៈ បរិក្ខា និងឱសថ
- កិច្ចសន្យាលើការផ្ដល់សេវាព្យាបាល ដែលអង្គការបង់ប្រាក់ជំនួសអ្នកជំងឺទៅតាមគម្រោង
- ធានារ៉ាប់រងសុខភាពសហគមន៍ ដែលអង្គការជួយអ្នកមានលទ្ធភាព តិចតួចដោយបង់ប្រាក់ទុកមុន ដើម្បីទូទាត់ការព្យាបាលជាក្រោយ
- មូលនិធិសមធម៌សម្រាប់ប្រជាជនក្រីក្រដែលទទួលការព្យាបាលឥតបង់ថ្លៃ និងការគាំទ្រផ្សេងៗ

## ចំណុចខ្វះខាត

- សុខភាពសាធារណៈដែលជាសិទ្ធិមូលដ្ឋានត្រូវបានបាត់បង់ ហើយពលរដ្ឋ បន្តធ្លាក់ក្នុងបំណុល និងភាពក្រីក្រដោយសារចំណាយលើការព្យាបាល
- គម្រោងអង្គការមានកម្រិតទាំងរយៈពេល និងសេវាគ្រប់ដណ្ដប់
- ខណៈពេលមានចំណូលតិច ពលរដ្ឋត្រូវបានជំរុញឱ្យរួមចំណែក ទិញធានារ៉ាប់រងសុខភាព
- កញ្ចប់ថវិកាមូលនិធិសមធម៌ពឹងផ្អែកលើជំនួយបរទេសច្រើនគ្មាននិរន្តភាព ហើយរដ្ឋដាក់ថវិកាតិចតួច

គេហទំព័រ ៖ www.unitedsisterhood.org



ស្តង់ដារសំណង់បន្ទប់ជួល
សិទ្ធិទទួលបានជម្រក និង លំនៅស្ថានសមរម្យ
សម្ភារៈបរិក្ខារ និង ទំនួលខុសត្រូវ
កំណត់តម្លៃ និង អត្រានៃការឡើងថ្លៃ
ដំណោះស្រាយជម្លោះកិច្ចសន្យា
រដ្ឋធានាផ្តល់សេវាទឹក ភ្លើង ប្រព័ន្ធលូ សំរាម និង សន្តិសុខ
• ស្រាវជ្រាវស្ថានភាព តំរូវការអ្នកជួល និង ម្ចាស់ផ្ទះជួល (ភស្តុតាង)
• កំណត់ស្តង់ដារសាងសង់អប្បបរមា និងតម្លៃ (ទំហំ បរិយាកាស លក្ខខណ្ឌនៃបន្ទប់)
• សង់បន្ទប់ជួលឬលំនៅដ្ឋានដល់អ្នកក្រ ក្នុងតម្លៃទាប ឬឥតបង់ថ្លៃនៅក្នុងទីប្រជុំជន
• ផ្តល់កម្ចីដែលមានការប្រាក់ទាប ដើម្បីសាងសង់ អគារ និង បន្ទប់ជួលខ្នាតតូច និង មធ្យម
• ត្រូវកំណត់ក្នុងកិច្ចសន្យាជាលាយលក្ខណ៍អក្សរ
• បន្ទប់តូចបំផុតត្រឹម១៥ដុល្លា (3mx5m)/១បន្ទប់ ក្នុងមួយខែ
• ឡើងថ្លៃគឺចន្លោះពី1$-5$ បន្ទាប់ពីរយៈពេល កិច្ចសន្យា២ឆ្នាំ ផ្អែកលើហេតុផល
• មានការជួលជាថ្ងៃ ឬជាខែ (១ខែទៅ២ឆ្នាំ)
• ផ្សព្វផ្សាយច្បាប់ភតិសន្យាពិសេស (ច្បាប់បន្ទប់ជួល)
• សម្របសម្រួលវិវាទដោយគ្មានការរើសអើង និងផ្តល់ កន្លែងស្នាក់នៅបណ្តោះអាសន្នដល់ អ្នកគ្មានលទ្ធភាព
• កំណត់ទោសទណ្ឌ យន្តការតាមដាន និងការផាក ពិន័យក្នុងច្បាប់លើករណីរំលោភកិច្ចសន្យា
• មានធុងសំរាមគ្រប់គ្រាន់ និងបែងចែកសំរាមសើម និងស្ងួត
• អាជ្ញាធរ និងអ្នកពាក់ព័ន្ធពង្រីកសេវាគ្របដណ្តប់ តំបន់បន្ទប់ជួលដោយប្រសិទ្ធិភាព
•រៀបចំយន្តការ និងក្រុមការងារត្រួតពិនិត្យ និងតាមដានការអនុវត្តឲ្យមានប្រសិទ្ធិភាព

# ច្បាប់ភតិសន្យាពិសេស

ភតិសន្យាពិសេស សំដៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាភតិបតី (ម្ចាស់ផ្ទះជួល) ឲ្យភាគីម្ខាងទៀតដែលជាកម្មករ សិស្ស និស្សិត ហៅថា ភតិកៈ (អ្នកជួលផ្ទះ) ប្រើប្រាស់ក្នុងការស្នាក់នៅដោយយកថ្លៃ។

## ចំណុចវិជ្ជមាន

- កិច្ចសន្យាត្រូវមានរយៈពេលយ៉ាងតិច២ឆ្នាំ
- ម្ចាស់ផ្ទះមិនអាចតម្លើងថ្លៃឈ្នួលបន្ទប់បានឡើយក្នុងរយៈពេលកិច្ចសន្យា
- កិច្ចសន្យាត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់
- ច្បាប់នេះអនុវត្តសម្រាប់សិស្ស និស្សិត និងកម្មករ (ក្នុង និងក្រៅប្រព័ន្ធ)
- អ្នកជួលផ្ទះមានសិទ្ធិរំលាយកិច្ចសន្យានៅពេលណាក៏បាន

## ចំណុចខ្វះខាត

- កិច្ចសន្យាមិនមានទម្រង់កំណត់ច្បាស់លាស់
- ច្បាប់មិនបានគ្របដណ្តប់ទូលំទូលាយលើស្ត្រីដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងមានជីវភាពលំបាកដូចជាស្ត្រីធ្វើការតាមគ្រឹះស្ថានកំសាន្ត ស្ត្រីប្រកបរបរផ្លូវភេទ អ្នកធ្វើការតាមផ្ទះ និងអ្នកលក់ដូរតាមផ្លូវ
- មិនមានការកំណត់ស្តង់ដារអប្បបរមានៃសំណង់ គុណភាពនិងសុវត្ថិភាពប្រព័ន្ធលូអនាម័យ សន្តិសុខ បរិយាកាសជុំវិញ

អាស័យដ្ឋាន ៖ ផ្ទះលេខ ៣ និង៤ ផ្លូវលេខ ៣៣៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ភ្នំពេញ

# កម្រងសំណួរស្វែងយល់ពីស្ថានភាពរស់នៅរបស់កម្មករក្នុងវិស័យឧស្សាហកម្មកាត់ដេរក្នុងប្រទេសកម្ពុជា

ឈ្មោះអ្នកសម្ភាសៈ.................................................... លេខទូរសព្ទ....................................................
ឈ្មោះអ្នកកត់ត្រាៈ...................................................... លេខទូរសព្ទ......................................................
ថ្ងៃខែសម្ភាសៈ.............................................................. ……………………………………………………..
ម៉ោងចាប់ផ្តើម................................ម៉ោងបញ្ចប់................................រយៈពេល.................................

**I . ព័ត៌មានទូទៅពីស្ថានភាពបន្ទប់ជួល**

តំបន់/ប្លុក……………………………………………………………………………….. ចំនួនជាន់…………………………
ចំនួនបន្ទប់សរុប……………………………………………………………………………………………………………
ចំនួនអ្នករស់នៅក្នុងបន្ទប់.....................................................................................................................
អាសយដ្ឋាន…………………………………………………………………………………………………………………
របង (មានឬអត់)……………… សាងសង់ពី………………………………………. កម្ពស់…………………………
អ្នកគ្រប់គ្រងផ្ទះជួលជា…………………………………………………….....ជនជាតិ…………………………………………

**II . ស្ថានភាពរស់នៅរបស់កម្មកររោងចក្រ**

**១. ស្តង់ដារបន្ទប់ជួល និងបរិក្ខារ**

**ក. ស្តង់ដារបន្ទប់ជួល**

1. តើបន្ទប់ជួលរបស់អ្នកមានទំហំប៉ុន្មាន?....................................តម្លៃប៉ុន្មាន?..................
2. តើម្ចាស់ផ្ទះជួលមានបទបញ្ជាផ្ទៃក្នុងដែរឬទេ?
   ☐ ក. មាន ☐ ខ.គ្មាន (*បើគ្មានរំលងទៅសំណួរទី ៤*)
3. តើបទបញ្ជានោះសមស្របដែរឬទេ?
   ☐ ក. សមស្រប
   ☐ ខ. មិនសមស្រប (ហេតុអ្វី?.........................................................................)
4. តើការជួលបន្ទប់របស់អ្នក មានកិច្ចសន្យាដែរឬទេ?
   ☐ ក. មាន (*បើមានរំលងទៅសំណួរទី ៧*)
   ☐ ខ. អត់មាន
5. បើអត់មាន តើអ្នកចង់មានកិច្ចសន្យាដែរឬទេ?
   ☐ ក. ចង់
   ☐ ខ. មិនចង់

☐ គ. អត់ដឹង

6. បើចង់ ឬមិនចង់ តើមូលហេតុអ្វី?.......................................................................................
......................................................................................................................................

7. តើថ្មីៗនេះបន្ទប់ជួលមានការឡើងថ្លៃឬទេ?

☐ ក. មាន ☐ ខ. គ្មាន *(បើគ្មានរំលងទៅសំណួរទី៩)*

8. បើមាន តើឡើងប៉ុន្មាន?............................ហេតុអ្វី? ........................................................
......................................................................................................................................

9. តើអ្នកប្រើប្រាស់ទឹក រដ្ឋ ឬឯកជន?

☐ ក. រដ្ឋ

☐ ខ. ឯកជន

10. តើតម្លៃប៉ុន្មាន?..............................................

11. តើអ្នកប្រើប្រាស់ភ្លើងរដ្ឋ ឬឯកជន?

☐ ក. រដ្ឋ

☐ ខ. ឯកជន

12. តើតម្លៃប៉ុន្មាន?..............................................

### ខ. បរិក្ខារបន្ទប់ជួល

13. តើបន្ទប់ជួលផ្ដល់សម្ភារៈប្រើប្រាស់អ្វីខ្លះ?

☐ ក. គ្រែ

☐ ខ. ទូខោអាវ

☐ គ. ធុងទឹក

☐ ឃ. កន្ទេល

☐ ង. ខ្នើយ

☐ ច. ធុងសំរាម

☐ ឆ. អត់មាន

☐ ជ. ផ្សេងៗ

14. នៅពេលបន្ទប់ជួលមានការខូចខាត( ឧទាហរណ៍ ដំបូលធ្លុះ ស្នះលូ ដាច់ភ្លើង ជ្រាបទឹក) (ដោយសារដល់អាយុកាល)តើអ្នកណាជាអ្នកជួសជុល?

☐ ក. ម្ចាស់ផ្ទះជួល

☐ ខ. អ្នកជួល

☐ គ. បដិភាគ

15. តើម្ចាស់បន្ទប់ជួលមានបំពាក់បំពង់ពន្លត់អគ្គិភ័យដែរឬទេ?

☐ ក. មាន

☐ ខ. គ្មាន **(បើគ្មានរំលងទៅសំណួរទី ១៧)**

16. បើមាន មានប៉ុន្មាន?..............................នៅកន្លែងណា?....................................

## ២. សន្តិសុខ និងសុវត្ថិភាព

### ក. អំពើចោរកម្ម

17. តើកន្លងមកធ្លាប់មានចោរលួចរបស់ប្រើប្រាស់ក្នុងបន្ទប់របស់អ្នកដែរឬទេ?

☐ ក.ធ្លាប់លួច

☐ ខ.អត់ទេ *(ប្រសិនបើអត់ រំលងទៅសំណួរទី២២)*

18. តើការលួចរបស់ប្រើប្រាស់តាមបន្ទប់កើតឡើងនៅពេលណា?

☐ ក.ពេលថ្ងៃ

☐ ខ.ពេលល្ងាច

☐ គ.ពេលយប់

☐ ឃ.ផ្សេងៗ (សូមបញ្ជាក់.......................................)

19. តើការលួចរបស់ប្រើប្រាស់តាមបន្ទប់កើតឡើងញឹកញាប់ប៉ុណ្ណា?

☐ ក.១ថ្ងៃទៅ៧ថ្ងៃ

☐ ខ.លើសពី១សប្តាហ៍ទៅមួយខែ

☐ គ.លើសពី១ខែ

20. នៅពេលមានចោរលួច តើអ្នករាយការណ៍ទៅនរណា?

☐ ក.ម្ចាស់ផ្ទះ

☐ ខ.មេភូមិ

☐ គ.មេប៉ុស្តិ៍

☐ ឃ.អត់បានរាយការណ៍ *(ប្រសិនបើអត់បានរាយការណ៍ រំលងទៅសំណួរទី ២២)*

☐ ង.ផ្សេងៗ (សូមបញ្ជាក់.............................................)

21. គាត់បានជួយអ្វីខ្លះ?..................................................................................................

..........................................................................................................................

22. តើកន្លងមកធ្លាប់មានចោរគាស់បន្ទប់របស់អ្នកដែរឬទេ?

☐ ក.ធ្លាប់គាស់

☐ ខ.អត់ទេ *(ប្រសិនបើអត់ រំលងទៅសំណួរទី ២៧)*

23. តើការគាស់បន្ទប់កើតឡើងនៅពេលណា?

☐ ក.ពេលថ្ងៃ

☐ ខ.ពេលយប់

☐ គ.ពេលល្ងាច

☐ ឃ.ផ្សេងៗ.............................................................................................

24. តើការគាស់បន្ទប់កើតឡើងញឹកញាប់ប៉ុណ្ណា ?

☐ ក.១ថ្ងៃទៅ៧ថ្ងៃ

☐ ខ.លើសពី១សប្តាហ៍ទៅមួយខែ

☐ គ.លើសពី១ខែ

25. នៅពេលមានចោរគាស់បន្ទប់ តើអ្នករាយការណ៍ទៅនរណា ?

☐ ក.ម្ចាស់ផ្ទះ

☐ ខ.មេភូមិ

☐ គ.មេប៉ុស្តិ៍

☐ ឃ.អត់បានរាយការណ៍ *(ប្រសិនបើអត់បានរាយការណ៍ រំលងទៅសំណួរទី ២៧)*

☐ ង.ផ្សេងៗ ( សូមបញ្ជាក់.......................................... )

26. គាត់បានជួយអ្វីខ្លះ ?..........................................................................................................

..........................................................................................................................................

**ខ. ការបំពាក់ភ្លើងបំភ្លឺផ្លូវ**

27. តើច្រកចេញចូលបន្ទប់ជួលរបស់អ្នកមានភ្លើងបំភ្លឺផ្លូវដែរឬទេ ?

☐ ក.មាន ☐ ខ.គ្មាន *(បើគ្មានរំលងទៅសំណួរទី ៣១)*

28. បើមាន តើគ្រប់គ្រាន់ឬអត់ ?

☐ ក.គ្រប់គ្រាន់ ☐ ខ.អត់គ្រប់គ្រាន់

តើភ្លើងនោះបិទម៉ោងប៉ុន្មាន បើកម៉ោងប៉ុន្មាន ?.........................................................................

29. តើនរណាជាអ្នកដាក់ភ្លើងបំភ្លឺផ្លូវនោះ ?

☐ ក.ម្ចាស់ផ្ទះជួល

☐ ខ.អ្នកជួលបន្ទប់

☐ គ.ផ្សេងៗ ( សូមបញ្ជាក់................................. )

30. ប្រសិនបើម្ចាស់ផ្ទះជួលជាអ្នកដាក់ភ្លើងបំភ្លឺផ្លូវនោះ គេយកលុយពីអ្នកជួលដែរឬទេ ?

☐ ក.យក (ប៉ុន្មាន ?........ ) ☐ ខ.មិនយក

**គ. បញ្ហាអសុវត្ថិភាព**

31. តើតំបន់/ប្លុករស់នៅរបស់អ្នកមានក្មេងស្ទាវដែរឬទេ ?

☐ ក.មាន ☐ ខ.គ្មាន *(បើគ្មានរំលងទៅសំណួរទី ៣៣)*

32. បើមាន តើកន្លងមកមានបញ្ហាអ្វីកើតឡើងខ្លះ ?

☐ ក.វាយតប់គ្នា

☐ ខ.ផឹកស្រាឡូឡា

☐ គ.បង្កការរំខានផ្សេងៗ

☐ ឃ.ផ្សេងៗ ( សូមបញ្ជាក់.......................................................... )

33. តើនៅកន្លែងរបស់អ្នកមានការជួញដូរ ឬប្រើប្រាស់គ្រឿងញៀនដែរឬទេ?

☐ ក.មាន ☐ ខ.គ្មាន ***(បើគ្មានរំលងទៅសំណួរទី ៣៦)***

34. បើមាន តើជួញដូរក្នុងរូបភាពយ៉ាងម៉េច? ............................................................................................

.........................................................................................................................................

35. តើការជួញដូរនោះ កើតឡើងនៅកន្លែងណា?..........................................................................................

.........................................................................................................................................

36. តើផ្ទះជួលនេះមានលេងល្បែងស៊ីសងដែរឬទេ?

☐ ក.មាន ☐ ខ.គ្មាន ***(បើគ្មានរំលងទៅសំណួរទី ៣៩)***

37. បើមាន តើល្បែងអ្វីខ្លះ?

☐ ក.ចាក់ឆ្នោត

☐ ខ.លេងបៀ

☐ គ.ជល់មាន់

☐ ឃ.អាប៉ោង

☐ ង.ផ្សេងៗ (សូមបញ្ជាក់..................................................................)

38. តើលេងនៅកន្លែងណាខ្លះ?..........................................................................................................

39. តើកន្លងមកអ្នកធ្លាប់រងការបៀតបៀនកេរ្តិ៍ខ្មាសដែរឬទេ?

☐ ក.ធ្លាប់ ☐ ខ.មិនធ្លាប់ ***(បើមិនធ្លាប់ រំលងទៅសំណួរទី ៤៧)***

40. បើធ្លាប់ តើក្នុងរូបភាពបែបណា?

☐ ក.លេបខាយពាក្យសំដី

☐ ខ.ប៉ះពាល់រាងកាយ

☐ គ. កាយវិការ

☐ ឃ. ផ្សេងៗ (សូមបញ្ជាក់............................................................)

41. តើវាកើតឡើងនៅពេលណា?

☐ ក.ពេលយប់

☐ ខ.ពេលថ្ងៃ

☐ គ.ពេលល្ងាច

☐ ឃ.ផ្សេងៗ (សូមបញ្ជាក់..........................................................................)

42. តើវាកើតឡើងនៅកន្លែងណា?

☐ ក.តាមផ្លូវទៅ-មកធ្វើការ

☐ ខ.កន្លែងធ្វើការ

☐ គ.កន្លែងរស់នៅ

☐ ឃ. ផ្សេងៗ (សូមបញ្ជាក់..........................................................................)

43. តើបញ្ហាបៀតបៀនកេរ្តិ៍ខ្មាសនេះកើតឡើងញឹកញាប់ប៉ុណ្ណា?

☐ ក.១ថ្ងៃទៅ៧ថ្ងៃ

☐ ខ.លើសពី១សប្តាហ៍ទៅមួយខែ

☐ គ.លើសពី១ខែ

☐ ឃ.ផ្សេងៗ (សូមបញ្ជាក់.............................................................................)

44. នៅពេលជួបបញ្ហាទាំងអស់នេះ តើអ្នកដោះស្រាយដូចម្តេច?...................................................

.........................................................................................................................

45. នៅពេលជួបបញ្ហាទាំងអស់នេះ តើកន្លងមកមានការអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋានដែរឬទេ?

☐ ក. មាន ☐ ខ.គ្មាន (*បើគ្មាន រំលងទៅសំណួរទៅ ៤៧*)

46. បើមាន តើអាជ្ញាធរមូលដ្ឋានអន្តរាគមន៍យ៉ាងដូចម្តេច?.............................................................

.........................................................................................................................

**ឃ. សន្តិសុខ**

47. តើអ្នកស្គាល់ប្រជាការពារភូមិ ឬសន្តិសុខភូមិដែរឬទេ?

☐ ក.ស្គាល់ ☐ ខ.មិនស្គាល់ (*បើមិនស្គាល់រំលងទៅសំណួរទី៤៩*)

48. បើស្គាល់ តើគាត់មានតួនាទី ធ្វើអ្វីខ្លះ?.........................................................................

.........................................................................................................................

49. តើនៅកន្លែងរស់នៅរបស់អ្នកមានប៉ុស្តិ៍ប៉ូលិសយាមដែរឬទេ?

☐ ក. មាន (មានប៉ុន្មានប៉ុស្តិ៍.................................)

☐ ខ. គ្មាន (*បើគ្មានរំលងទៅសំណួរទី ៥១*)

50. ប្រសិនបើមាន តើប៉ុស្តិ៍យាមនោះមានប៉ូលិសឬអត់?

☐ ក. មាន

☐ ខ. គ្មាន

## ៣. សុខភាព និងអនាម័យ

**ក. បង្គន់អនាម័យ និងបន្ទប់ងូតទឹក**

51. តើនៅកន្លែងដែលអ្នកជួលបន្ទប់មានបង្គន់អនាម័យដែរឬទេ?

☐ ក. មាន ☐ ខ. អត់មានទេ (*បើអត់មានរំលងទៅសំណួរទី ៥៩*)

52. បើមាន តើមានបង្គន់អនាម័យចំនួនប៉ុន្មាន?..................

53. ប្រសិនបើមាន តើបង្គន់អនាម័យនៅក្នុងបន្ទប់ជួលរបស់អ្នក ឬប្រើប្រាស់រួមគ្នា?

☐ ក. បង្គន់អនាម័យផ្ទាល់ខ្លួននៅក្នុងបន្ទប់ជួល

☐ ខ. បង្គន់អនាម័យប្រើប្រាស់រួមគ្នា ដោយអ្នកជួលបន្ទប់មួយចំនួន

☐ គ. បង្គន់អនាម័យប្រើប្រាស់រួមគ្នា ដោយអ្នកជួលបន្ទប់ទាំងអស់

54. តើបង្គន់អនាម័យប្រើប្រាស់សម្រាប់មនុស្សប៉ុន្មាននាក់?.........................

55. សូមមើលបង្គន់អនាម័យដោយផ្ទាល់ តើបង្គន់មានអនាម័យដែរឬទេ?

*(សូមអ្នកសម្ភាសន៍ទៅមើលបង្គន់ រួច (✓) នៅក្នុងចម្លើយខាងក្រោម)*

☐ ក. មានអនាម័យ៖ អត់មានក្លិនស្អុយ អត់ឃើញលាមក អត់រុយរោម

☐ ខ. អត់មានអនាម័យ៖ មានក្លិនស្អុយតិចតួច ឃើញលាមកខ្លះៗ មានរុយរោមតិចតួច

☐ គ. កខ្វក់៖ មានក្លិនស្អុយខ្លាំង ឃើញលាមកច្រើន មានរុយរោមច្រើន

56. នៅពេលអ្នកបន្ទោរបង់ តើបង្គន់មានអ្វីការពារដើម្បីកុំឲ្យអ្នកដទៃមើលឃើញនិងស្តាប់លឺដែរឬទេ?

☐ ក. ភាពឯកជនត្រូវបានបិទបាំង (មានដំបូលបិទជិត ជញ្ជាំងបិទបាំងជិត ទ្វារបិទជិត)

☐ ខ. គ្មានភាពឯកជន៖ អាចមើលឃើញ

☐ គ. គ្មានភាពឯកជន៖ អាចស្តាប់លឺ

☐ ឃ. គ្មានភាពឯកជន៖ អាចមើលឃើញ និងស្តាប់លឺ

57. តើបង្គន់អនាម័យឆ្ងាយពីបន្ទប់ជួលរបស់អ្នកដែរឬទេ? ☐ ក. ចាស ☐ ខ. ទេ

58. តើផ្លូវដើរទៅបង្គន់អនាម័យមានភ្លើងបំភ្លឺដែរឬទេ? ☐ ក. មាន ☐ ខ. អត់មាន

59. តើអ្នករួមបន្ទប់ជាមួយអ្នកបន្ទោរបង់នៅក្នុងបង្គន់ ឬបន្ទោរបង់នៅវាល?

☐ ក. គ្រប់គ្នាប្រើប្រាស់បង្គន់

☐ ខ. អ្នកខ្លះបន្ទោរបង់នៅវាល

☐ គ. មិនប្រើបង្គន់ទាំងអស់គ្នា

☐ ឃ. ផ្សេងៗ (សូមបញ្ជាក់.............................)

60. តើអ្នកមានកូនតូចនៅជាមួយអ្នកដែរឬទេ? ☐ ក. មាន ☐ ខ. អត់មាន **(បើអត់មាន រំលងទៅសំណួរទី ៦២)**

61. ប្រសិនបើមាន តើលាមកកូនរបស់អ្នកចោលនៅកន្លែងណា?

☐ ក. ចាក់ចូលទៅក្នុងបង្គន់

☐ ខ. ចោលជាមួយសំរាម

☐ គ. ចោលទៅទីវាល

☐ ឃ. ចោលទៅក្នុងលូ

☐ ង. កប់ដី

☐ ច. ចោលនៅកន្លែងផ្សេងៗ (សូមបញ្ជាក់..............................)

62. តើពេលអ្នកងូតទឹករួមមានសុវត្ថិភាពឬអត់? ☐ មាន(**បើមាន រំលងទៅសំណួរទី ៦៤**) ☐ អត់មាន

63. ប្រសិនបើគ្មានសុវត្ថិភាព ហេតុអ្វី?.............................................................................

..............................................................................................................................

**ខ. បរិស្ថាន និងបរិយាកាសបន្ទប់ជួល**

64. តើបរិស្ថានជុំវិញបន្ទប់ជួលរបស់អ្នកយ៉ាងដូចម្តេច? ទាំងខាងក្នុង និងខាងក្រៅ (ឧទាហរណ៍ ទីធ្លាតូចចង្អៀត ធំទូលាយ ខ្យល់អាកាស )............................................... ...... ..................

................ ......................... .................. ...................................................................

65. តើបន្ទប់របស់អ្នកមានពន្លឺគ្រប់គ្រាន់ឬទេ?

☐ ក. គ្រប់គ្រាន់ ☐ ខ. មិនគ្រប់គ្រាន់ទេ ***(បើមិនគ្រប់គ្រាន់រំលងទៅសំណួរទី ៦៧)***

66. បើគ្រប់គ្រាន់ តើពន្លឺមានប្រភពមកពីណា?

☐ ក. អំពូលអគ្គិសនី ☐ ខ. ពន្លឺថ្ងៃ

67. បើអត់គ្រប់គ្រាន់ តើមានអំពូលអគ្គិសនីបំភ្លឺដែរឬអត់?

☐ ក. មាន ☐ ខ. អត់

68. តើបន្ទប់ជួលរបស់អ្នកមានកន្លែងហាលខោអាវសមរម្យ ឬអត់?

☐ ក.សមរម្យ (ចូររៀបរាប់..........................................................................................)

☐ ខ.មិនសមរម្យ (ហេតុអ្វី.......................................................................................)

## គ. ចំណីអាហារ និងទឹក

69. តើអាហារដែលអ្នកញ៉ាំមានអនាម័យដែរឬអត់?

☐ ក.មាន (បញ្ជាក់...................................................................................................)

☐ ខ.អត់ (ហេតុអ្វី?................................................................................................)

70. តើទឹកដែលអ្នកប្រើសម្រាប់ដាំស្ល និងធ្វើម្ហូប មានប្រភពមកពីណា?

☐ ក. ទឹកទន្លេ

☐ ខ. ទឹកអណ្តូង

☐ គ.ទឹកចេញពីក្បាលរ៉ូប៊ីណេ

☐ ឃ. ផ្សេងៗ ...........................................................................................

71. តើទឹកនោះ អ្នកប្រើដោយវិធីណា?

☐ ក. ប្រើទឹកពាងផ្ទាល់ ដោយមិនមានគ្រប និងមិនបានលាងសម្អាត

☐ ខ. ប្រើទឹកពាងផ្ទាល់ ដោយគ្របត្រឹមត្រូវ និងលាងសម្អាត

☐ គ. ដងពីពាង ដាក់ចូលក្នុងធុងមានគ្របត្រឹមត្រូវ

☐ ឃ. ប្រើផ្ទាល់ពីក្បាលរ៉ូប៊ីណេ

☐ ង. ផ្សេងៗ (សូមបញ្ជាក់..............................)

72. តើទឹកដែលអ្នកបរិភោគរាល់ថ្ងៃជាទឹកអ្វី?

☐ ក. ទឹកសុទ្ធ

☐ ខ. ទឹកដាំឆ្អិន

☐ គ. ទឹកមិនដាំ

☐ ឃ. ទឹកចម្រោះ

## ឃ. អនាម័យ

73. តើកន្លែងលាងដៃរបស់អ្នកនៅកន្លែងណា?

☐ ក. នៅជិតចង្ក្រាន

☐ ខ. នៅជិតពាងទឹក

☐ គ. នៅជិតបង្គន់

☐ ឃ. អត់មានកន្លែងដាក់លាក់

☐ ង. នៅកន្លែងផ្សេង (សូមបញ្ជាក់..........................)

74. តើនៅកន្លែងលាងដៃមានទឹក និងសាប៊ូដែរឬទេ?

☐ ក. មានទឹក

☐ ខ. មានសាប៊ូ

☐ គ. គ្មាន

75. តើទឹក និងសាប៊ូសម្រាប់លាងដៃនៅចំងាយ៥ម៉ែត្រពីកន្លែងលាងដៃដែរឬទេ?

☐ ក. ចាស ☐ ខ. ទេ

76. តើអ្នកលាងដៃរបស់អ្នកនៅពេលណា?

☐ ក. បន្ទាប់ពីបន្ទោរបង់រួច

☐ ខ. មុនពេលញ៉ាំអាហារ

☐ គ. ក្រោយពេលញ៉ាំអាហារ

☐ ឃ. មុនពេលធ្វើម្ហូប

☐ ង. បន្ទាប់លាងគូថកូនក្មេង

☐ ច. មុនពេលបញ្ចុកអាហារកូនក្មេង

☐ ឆ. ផ្សេងៗ.................................................................................

## ង. កាកសំណល់

77. តើសំរាមយកទៅចោលឯណា?

☐ ក. ដាក់ចោលក្នុងបន្ទប់

☐ ខ. ដាក់ធុងសំរាមក្នុងបន្ទប់

☐ គ. ដាក់ធុងសំរាមក្រៅបន្ទប់

☐ ឃ. ដាក់ធុងសំរាមរួម

☐ ង. ទុកចោលទីវាលសាធារណៈ (សូមបញ្ជាក់.......................................)

78. តើអ្នកបង់ថ្លៃសេវាសំរាមដែរឬទេ?

☐ ក. បង់ (តម្លៃប៉ុន្មាន?..............................................)

☐ ខ. អត់បង់

## ច. ស្ថានភាពសុខភាព

79. តើមួយឆ្នាំចុងក្រោយនេះ សុខភាពរបស់អ្នកមានស្ថានភាពយ៉ាងដូចម្តេច?

☐ ក. ល្អ (រៀបរាប់..............................................................................)

☐ ខ. ធម្មតា (រៀបរាប់..........................................................................)

☐ គ. ចុះខ្សោយ (រៀបរាប់......................................................................)

☐ ឃ. ទ្រុឌទ្រោម (រៀបរាប់..........................................................................................)

80. តើពេលមានជំងឺ អ្នកទៅរកសេវាព្យាបាលនៅឯណា?

☐ ក. គ្លីនីកឯកជន

☐ ខ. មណ្ឌលសុខភាព

☐ គ. មន្ទីរពេទ្យ

☐ ឃ.ឱសថស្ថាន

☐ ង. ផ្សេងៗ..................................................................................................

81. ប្រសិនបើអ្នកប្រើប្រាស់សេវានៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ តើអ្នកពេញចិត្តនឹងសេវាព្យាបាលដែរឬទេ?

☐ ក. ពេញចិត្ត (ចូររៀបរាប់.......................................................................................)

☐ ក. មិនពេញចិត្ត (ហេតុអ្វី.......................................................................................)

82. តើជាមធ្យមអ្នកចំណាយម្តងអស់ប៉ុន្មានលើថ្លៃព្យាបាល?

☐ ក. 0 – 20,000 រៀល

☐ ខ. 20,100 – 50,000 រៀល

☐ គ. 50,100 – 100,000 រៀល

☐ ឃ. 100,100 – 200,000 រៀល

☐ ង. លើសពី 200,000 រៀល

83. តើអ្នកគិតថា តម្លៃនេះសមរម្យដែរឬទេ?

☐ ក. សមរម្យ (បញ្ជាក់.........................................)

☐ ខ. មិនសមរម្យ (បញ្ជាក់......................................)

## ឆ. ប្រព័ន្ធលូ

84. តើកន្លែង/ផ្ទះជួលរបស់អ្នកមានលូប៉ុន្មាន?...................................................................
ដាក់នៅកន្លែងណាខ្លះ?...........................................................................................

85. តើកន្លែងរស់នៅរបស់អ្នកមានស្ទះលូដែរឬទេ?

☐ ក. ស្ទះ

☐ ខ. អត់ស្ទះ

86. ប្រសិនបើស្ទះ តើស្ទះនៅពេលណា?........................................មូលហេតុអ្វី?..........................
.......................................................................................................................

សម្ព័ន្ធបងប្អូនស្រី
United Sisterhood Alliance

FOCUS ON THE GLOBAL SOUTH

សមាគមមណ្ឌលព័ត៌មានកម្មករ
WORKER'S INFORMATION CENTER


អាសយដ្ឋាន: ផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទូរស័ព្ទ: ០១៧ ២២៩ ៥០០
អ៊ីមែល: communication.wic@gmail.com
គេហទំព័រ: www.wic.unitedsisterhood.org